**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ ពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ករណី ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **សំបូរ ស្រីណុច**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ សំបូរ ស្រីណុច ជានិស្សិតចងក្រងសារណានេះ សូមគោរពនិងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះលោកឪពុកនិងអ្នកម្តាយដែលលោកបានផ្តល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងគ្រប់បែបយ៉ាងទាំងស្មារតីនិងសម្ភារៈ ជាពិសេសលោកទាំងពីរបានផ្តល់ឱកាសដ៏មានតម្លៃឲ្យនាងខ្ញុំបានសិក្សារៀនសូត្ររហូតមកដល់ពេលបច្ចុប្បន្ននេះ។

ជាបន្ទាប់នាងខ្ញុំសូមអរគុណ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក និងលោកស្រីសាស្ត្រាចារ្យទាំងអស់នៃថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបណ្តុះបណ្តាលរូបនាងខ្ញុំកន្លងមករួមទាំងនិស្សិតដទៃទៀតផងដែរ។

លើសពីនេះទៅទៀត នាងខ្ញុំក៏សូមគោរពនិងសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងនាមជាសាស្ត្រាចារ្យណែនាំ ដោយបានជួយណែនាំជ្រោមជ្រែងខិតខំយកចិត្តទុកដាក់ត្រួសត្រាយផ្លូវសម្រាប់រូបនាងខ្ញុំ និងបានផ្តល់នូវទស្សនទានល្អៗយ៉ាងច្រើនដែលធ្វើឲ្យនាងខ្ញុំបានបញ្ចប់នូវការចងក្រងសារណាមួយនេះប្រកបដោយជោគជ័យគួរជាទីមោទនៈ។

ជាចុងក្រោយ នាងខ្ញុំសូមធ្វើការអរគុណរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលបានដឹកនាំប្រទេសកម្ពុជាប្រកបដោយសុខសន្តិភាពរីកចម្រើននិងអភិវឌ្ឍន៍ឥតឈប់ឈរទើបនាងខ្ញុំនិង និស្សិតដទៃទៀតមានឱកាសក្នុងការសិក្សាស្រាវជ្រាវនិងចងក្រងនូវស្នាដៃថ្មីៗ ដើម្បីជាប្រយោជន៍រួមក្នុងការចែករំលែកនូវចំណេះដឹងនានាទៅកាន់និស្សិតដទៃទៀត ក៏ដូចជាផ្នែកមួយនៃការចូលរួមអភិវឌ្ឍធនធានមនុស្សនៃសង្គមជាតិយើងផងដែរ។

# អារម្ភកថា

នៅក្នុងពេលបច្ចុប្បន្ន មជ្ឈត្តការពាណិជ្ជកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទពាណិជ្ជ-កម្មសម្រាប់អ្នកជំនួញទូទាំងសកលលោក ពីព្រោះវាមានប្រសិទ្ធភាពខ្ពស់ រហ័ស និងរក្សាការសម្ងាត់ខុសពីតុលាការជាតិ។ ដូចនេះហើយ ទើបមជ្ឈត្តការពាណិជ្ជកម្មមានភាពពេញនិយមខ្លាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ក៏ប៉ុន្តែ ក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនដោយរាប់បញ្ចូលទាំងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការពាណិជ្ជកម្មមានឧបសគ្គក៏ដូចជាបញ្ហាខ្លះៗកើតមានឡើងពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ ឬទាក់ទងនឹងចំណេះដឹងបច្ចេកទេសនៃផ្នែកមជ្ឈត្តការពាណិជ្ជកម្ម។

ហេតុដូចបានរៀបរាប់ខាងលើ ការសិក្សាស្វែងយល់បន្ថែមអំពីមជ្ឈត្តការពាណិជ្ជកម្មក្នុងដំណើរការនៃនីតិវិធីមជ្ឈត្តការក៏ដូចជាលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីឲ្យមជ្ឈត្តការមានសមត្ថកិច្ចទៅលើវិវាទរបស់ភាគី (ភាគីនៃវិវាទព្រមព្រៀងបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មប្រកបដោយសុពលភាព) ការយល់ដឹងអំពីសិទ្ធិនានា និងការអនុវត្តសិទ្ធិរបស់ភាគីក្នុងមជ្ឈត្តការ គឺជាការចាំបាច់សម្រាប់ការពារផលប្រយោជន៍របស់ភាគីនៃមជ្ឈត្តការ និងដើម្បីបញ្ចៀសនូវការរំលោភបំពានពីអ្នកដទៃឬភាគីម្ខាងទៀតដោយមិនដឹងខ្លួនជាដើម។

កត្តាដូចបានរៀបរាប់ខាងលើនេះបានជំរុញឲ្យនាងខ្ញុំសិក្សាស្រាវជ្រាវប្រធានបទស្តីពី សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចក្នុងករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី ដោយស្ថិតក្រោមការបង្ហាត់បង្ហាញពីសំណាក់សាស្ត្រាចារ្យណែនាំ ក្នុងគោលបំណងស្រាវជ្រាវនិងបកស្រាយចំណុចសំខាន់ៗដែលទាក់ទងនឹងប្រធានបទនេះ ដើម្បីចែករំលែកនូវចំណេះដឹងទៅដល់និស្សិតនិងមិត្តអ្នកអានទាំងអស់គ្នា។

ដោយហេតុថាពេលវេលានៃការស្រាវជ្រាវរួមទាំងពេលវេលានៃការចងក្រងមានកម្រិត ព្រមទាំងកង្វះខាតនៃឯកសារជាតិ និងអន្តរជាតិមួយចំនួនទាក់ទងនឹងប្រធានបទ នាងខ្ញុំសូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គងដោយ អចេតនាគ្រប់ប្រការណាមួយដែលអាចនឹងកើតឡើងតួយ៉ាង ដូចជាកំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេជន៍ វេយ្យាករណ៍ និងឃ្លាល្បះណាមួយមិនបានត្រឹមត្រូវជាដើម។ ម៉្យាងទៀត នាងខ្ញុំរីករាយនិងសូមស្វាគមន៍ជានិច្ចចំពោះការរិះគន់ផ្សេងៗពីសំណាក់អ្នកអានទាំងអស់ ដើម្បីធ្វើការស្ថាបនាការស្រាវជ្រាវលើកក្រោយរបស់នាងខ្ញុំឲ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត៕

# មាតិកា


ទំព័រ

**អក្សរកាត់** ........ iii

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**

**សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម**

**ផ្នែកទី១ ច្បាប់ដែលភាគីទាំងអស់ត្រូវគោរពតាម** ........ ៥

១.១. ច្បាប់កិច្ចសន្យា ........ ៦

១.១.១. ច្បាប់កិច្ចសន្យាអន្តរជាតិ ........ ៦

១.១.១.១. អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ........ ៦

១.១.១.២គោលការណ៍ .UNIDROITនៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ ........ ៧

១.១.២. ច្បាប់កិច្ចសន្យាជាតិ ........ ៧

១.១.២.១. ក្រមរដ្ឋប្បវេណីកម្ពុជា ........ ៨

១.១.២.២. ច្បាប់ស្ដីពីកិច្ចសន្យាម៉ាឡេស៊ី ........ ១០

១.២. ច្បាប់មជ្ឈត្តការពាណិជ្ជកម្ម ........ ១៤

១.២.១. ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា ........ ១៦

១.២.២. ច្បាប់ស្ដីពីមជ្ឈត្តការម៉ាឡេស៊ី ........ ១៨

១.៣. វិធានមជ្ឈត្តការពាណិជ្ជកម្ម ........ ១៩

១.៣.១. វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........ ២០

១.៣.២. វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី ........ ២០

**ផ្នែកទី២ ច្បាប់ឬលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលអាចអនុវត្តបានក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម** ........ ២១

**ជំពូកទី២**

**ប្រៀបធៀបសុពលភាពនៃកិច្ចព្រមព្រៀង**

**មជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងបញ្ហាប្រឈម**

**ផ្នែកទី១ ប្រៀបធៀបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី** ........ ២៦

១.១. លក្ខណៈដូច ........ ២៧

១.១.១. ច្បាប់កិច្ចសន្យាជាតិ ........................................................................................................ ២៧
១.១.២. ច្បាប់មជ្ឈត្តការ .............................................................................................................. ២៨
១.១.៣. វិធានមជ្ឈត្តការ ............................................................................................................... ២៩
១.២. លក្ខណៈខុស ........................................................................................................................ ២៩
១.២.១. ច្បាប់កិច្ចសន្យា ................................................................................................................ ២៩
១.២.២. ច្បាប់មជ្ឈត្តការ ............................................................................................................... ៣០
១.២.៣. វិធានមជ្ឈត្តការ ............................................................................................................... ៣០
**ផ្នែកទី២ បញ្ហាប្រឈមនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី** ............................................ ៣១
១.១. ករណីកម្ពុជា ......................................................................................................................... ៣១
១.២. ករណីម៉ាឡេស៊ី ...................................................................................................................... ៣១
**សេចក្តីសន្និដ្ឋាន** .......................................................................................................................... ៣៤
**អនុសាសន៍** ................................................................................................................................... ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| AIAC | Asian International Arbitration Centre |
| CISG | United Nations Convention on Contract for the International Sale of Goods |
| HKIAC | Hong Kong International Arbitration Centre |
| ICC | International Chamber of Commerce |
| KLRCA | Kuala Lumpur Regional Centre for Arbitration |
| LCIA | The London Court of International Arbitration |
| MCIA | Mumbai Centre for International Arbitration |
| New York Convention | Convention on the Recognition and Enforcement of Foreign Arbitral Awards 1958 |
| NCAC | National Commercial Arbitration Centre |
| QICCA | Qatar International Center for Conciliation and Arbitration |
| SIAC | Singapore International Arbitration Centre |
| UNCITRAL Model Law | UNCITRAL Model Law on International Commercial Arbitration |
| UPICC | UNIDROIT Principles of International Commercial Contracts |

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

វិស័យពាណិជ្ជកម្មនៅក្នុងពិភពលោកកាន់តែមានភាពរីកចម្រើនឡើងៗ រីឯវិវាទឬជម្លោះពាណិជ្ជកម្មជាតិ និងអន្តរជាតិក៏មានការកើនឡើងទន្ទឹមគ្នាគួរឲ្យកត់សម្គាល់ផងដែរ។ នាពេលបច្ចុប្បន្ន នៅពេលដែលមានវិវាទពាណិជ្ជកម្មកើតឡើង ភាគីគឺមិននិយមធ្វើការដោះស្រាយវិវាទពាណិជ្ជកម្មរបស់ខ្លួនតាមប្រព័ន្ធតុលាការដូចមុនឡើយ ពោលគឺពួកគេនិយមដោះស្រាយតាមយន្តការក្រៅប្រព័ន្ធតុលាការវិញ។ មជ្ឈត្តការពាណិជ្ជកម្មគឺជាយន្តការមួយក្នុងចំណោមយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលត្រូវបានបែងចែកចេញជា មជ្ឈត្តការជាតិ និងមជ្ឈត្តការអន្តរជាតិ។ មជ្ឈត្តការជាតិគឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលសេចក្ដីសម្រេចមានអានុភាពចាប់បង្ខំនិងស្ថាពរ។ រីឯមជ្ឈត្តការអន្តរជាតិវិញគឺយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានសមត្ថកិច្ចរួមទាំងអានុភាពចាប់បង្ខំនិងស្ថាពរទូលំទូលាយជាងមជ្ឈត្តការជាតិ។ គួរបញ្ជាក់ផងដែរថា រាល់ដំណើរការមជ្ឈត្តការពាណិជ្ជកម្មត្រូវប្រព្រឹត្តដោយផ្អែកលើមូលដ្ឋានច្បាប់ និងគោលការណ៍សមធម៌ដែលមិនមែនជាបទដ្ឋានច្បាប់( Ex aequo et bono)។

ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការគឺមានច្រើនប្រភេទ ដែលជាទូទៅកើតមានឡើងដោយផ្អែកលើការព្រមព្រៀងស្ម័គ្រចិត្តរបស់គូភាគីថានឹងដោះស្រាយវិវាទដែលកើតមាននៅពេលអនាគត ឬកើតនៅក្នុងពេលបច្ចុប្បន្ន។[1] ការដោះស្រាយត្រូវធ្វើឡើងតាមរយៈមជ្ឈត្តករ ដែលត្រូវបានជ្រើសរើសដោយភាគីនៃវិវាទដើម្បីមានអំណាចនិងសមត្ថកិច្ចក្នុងការផ្ដល់សេចក្ដីសម្រេចតាមរយៈច្បាប់ជាធរមាន។ ចំពោះករណីមជ្ឈត្តការពាណិជ្ជកម្មវិញ គូភាគីអាចដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តការបានលុះត្រាតែគូភាគីបានធ្វើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលអាចស្ថិតនៅក្នុងទម្រង់នៃខសន្យាមជ្ឈត្តការ( *Arbitration Clause* ) ឬអាចបង្កើតជាលក្ខណៈកិច្ច ព្រមព្រៀងមជ្ឈត្តការដោយឡែក( *Arbitration Agreement* )។

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មទាំងពីរប្រភេទគឺមានជាទម្រង់គម្រូសម្រាប់ឲ្យគូភាគីសរសេរតាមដោយភ្ជាប់នឹងចំណុចគោលសំខាន់ៗ ដែលមជ្ឈត្តការតម្រូវឲ្យមានដើម្បីបញ្ជាក់ពីឆន្ទៈរបស់គូភាគីក្នុងការជ្រើសរើសមជ្ឈត្តការក៏ដូចជានីតិវិធីច្បាប់ណាមួយក្នុងការដោះស្រាយវិវាទរបស់ពួកគេ។ ប៉ុន្តែគូភាគីអាចធ្វើការសរសេរបន្ថែម ឬមិនសរសេរនូវចំណុចមិនចាំបាច់ដែលគូភាគីមិនចង់ដាក់ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួនក៏បានដែរ ព្រោះវាគឺជាស្វ័យភាពបុគ្គលក្នុងការសម្រេច។

[1] LexisNexis, "Arbitration agreements – definition, purpose and interpretation", *The Arbitration Agreement,* អាចរកបាននៅ https://www.lexisnexis.co.uk/legal/guidance/arbitration-agreements-definition-purpose-and-interpretation (ចូលទស្សនាថ្ងៃទី២៨ មេសា ២០២០)។

ជាចម្បង ទម្រង់សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគឺមិនមែនផ្ដោតទៅលើតែទម្រង់សរសេរ ឬមិនសរសេរដែលបង្កើតឡើងដោយភាគីនោះទេ។ ដោយយោងលើស្វ័យភាពបុគ្គលក្នុងការសម្រេចនូវការសរសេរបន្ថែម ឬមិនសរសេរនូវចំណុចចាំបាច់បាន ទើបធ្វើឲ្យរាល់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលបានបង្កើតទាំងអស់មិនមែនសុទ្ធតែមានសុពលភាពទេ ទោះបីជាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបង្កើតឡើងស្របនឹងលក្ខខណ្ឌទម្រង់ក៏ដោយ ពីព្រោះករណីមួយចំនួនគឺកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបានបង្កើតឡើងដោយមានវិការៈ។ ហេតុដូចនេះហើយទើបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមិនសំដៅទៅលើតែការបំពេញនូវលក្ខខណ្ឌទម្រង់តែប៉ុណ្ណោះទេ លក្ខខណ្ឌសារធាតុនៃទម្រង់សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក៏ចាត់ទុកជាលក្ខខណ្ឌចាំបាច់មួយបន្ថែមទៀត ដែលភាគីពាក់ព័ន្ធគ្រប់រូបគួរសិក្សាស្វែងយល់ ដោយសារតែកត្តាមូលដ្ឋានច្បាប់ជាច្រើនប្រភេទអាចធ្វើឲ្យកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអសុពលភាពបាន ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានលក្ខណៈផ្ទុយនឹងបញ្ញត្តិណាមួយដែលបានកំណត់នៅក្នុងច្បាប់ដែលភាគីទាំងអស់ត្រូវគោរពតាម។

បញ្ហាគតិយុត្តចោទឡើងក្នុងអត្ថបទសារណាគឺ តើសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវបង្កើតឡើងដោយឈរលើមូលដ្ឋានច្បាប់អ្វីខ្លះ? តើវាមានបញ្ហាប្រឈមផ្សេងទៀតដែរឬទេ ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលភាគីបានបង្កើតឡើងដោយមិនស្របតាមលក្ខខណ្ឌសុពលភាព?

ដើម្បីឆ្លើយតបនឹងបញ្ហាគតិយុត្តិខាងលើ យើងគប្បីគួរសិក្សាស្វែងយល់ឲ្យបានច្បាស់អំពីសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ដើម្បីកាត់បន្ថយនូវបញ្ហាអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក៏ដូចជាការពារផលប្រយោជន៍ដល់ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបន្ថែមទៀត។ ជាក់ស្ដែងអត្ថបទសារណាមួយនេះនឹងបកស្រាយទៅលើប្រធានបទ និងបង្ហាញនូវដំណោះស្រាយមួយចំនួនទាក់ទងនឹងបញ្ហាគតិយុត្តដោយបែងចែកចេញជាពីរជំពូកគឺ៖ **ជំពូកទី១ សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម និង ជំពូកទី២ បញ្ហាប្រឈមនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី។**

# ជំពូកទី១

# សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម

## ជំពូកទី១ សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម

ជាទូទៅ មជ្ឈត្តការគឺកើតមានឡើងដោយសារតែភាគីដែលមានសមត្ថភាពគ្រប់គ្រាន់ធ្វើការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការជាមួយគ្នាដោយភ្ជាប់នឹងការយល់ព្រមដោយសេរីរបស់ពួកគេ។[2] កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មពិតជាមានសារៈសំខាន់ចំពោះការបញ្ជាក់ពីយុត្តាធិការ និងអំណាចរបស់វេទិកាមជ្ឈត្តកម្មក្នុងការសម្រេចអំពីវិវាទដែលកកើតពីឆន្ទៈរបស់គូភាគីដែលបានព្រមព្រៀងគ្នា។[3] ក៏ប៉ុន្តែបញ្ហាទាក់ទងនឹងសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅតែមានបញ្ហាចោទជាច្រើន ដោយសារតែសមត្ថភាពនៃវិស័យមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍនៅមានកម្រិត ឬខ្លះទៀតទើបតែចាប់ផ្តើមមានដំណើរការ ជាហេតុធ្វើឲ្យមានកង្វះខាតចំណេះដឹងទាក់ទងនឹងប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្មជាច្រើនផងដែរ។

ជាមូលដ្ឋានគ្រឹះ យុត្តាធិការនៃមជ្ឈត្តការកកើតមានឡើងដោយយោងទៅលើគោលការណ៍យុត្តាធិការវេទិកាមជ្ឈត្តកម្ម (*Kompetenz-Kompetenz Principle*)។ ប៉ុន្តែ យុត្តាធិការវេទិការមជ្ឈត្តកម្មមិនអាចមានសុពលភាព គ្របដណ្តប់គ្រប់រឿងក្តីនោះទេ ហេតុនេះហើយការអនុវត្តគោលការណ៍យុត្តាធិការទាក់ទងនឹងបញ្ហាគតិយុត្តនៃ សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានសារៈសំខាន់ក្នុងការបែងចែក និងដោះស្រាយអត្ថិភាពនៃ ការយល់ព្រមរបស់ភាគីលើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ដើម្បីពិចារណាថាតើមជ្ឈត្តការឬតុលាការជាតិ ទើបជាស្ថាប័នពិតប្រាកដដែលមានយុត្តាធិការដោះស្រាយវិវាទ ក្នុងគោលបំណងដើម្បីបញ្ចៀសនូវវិវាទយុត្តាធិ-ការរវាងមជ្ឈត្តការនិងតុលាការជាតិ។ លើសពីនេះទៅទៀត គោលការណ៍យុត្តាធិការវេទិការមជ្ឈត្តកម្មគឺផ្តល់អំ- ណាចក្នុងការវិនិច្ឆ័យអំពីយុត្តាធិការរបស់ខ្លួន ដោយរួមបញ្ចូលទាំងការជំទាស់នានាដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ឬវិសាលភាពអនុវត្តនៃកិច្ចព្រមព្រៀងមជ្ឈត្តការវិវាទពាណិជ្ជកម្មបង្កើតដោយគូភាគី។[4] ជាទូទៅកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចធ្វើឡើងតាមការព្រៀមព្រៀងរបស់គូភាគីទៅលើលក្ខខណ្ឌនានា ឬនីតិវិធីផ្សេងៗក្នុងការដោះស្រាយវិវាទ ប៉ុន្តែមិនត្រូវឲ្យមានការបំពានទៅលើគោលការណ៍គ្រឹះនៃមជ្ឈត្តការនោះទេ។[5]

---

[2] Moses, Margaret L. *The Principles and Practice of International Commercial Arbitration*, New York: Cambridge University Press ឆ្នាំ២០០៨, ទំព័រ១៨។

[3] Fouchard, Philippe, Gailard Emmanuel, Goldman Berthold. *International Commercial Arbitration*, London: Kluwer Law International ឆ្នាំ ១៩៩៩, ទំព័រ២៩, កថាខណ្ឌទី៤៤។

[4] Born, Gary B. *International Commercial Arbitration*, 2nd edition, London: Kluwer Law International ឆ្នាំ២០១៤, ទំព័រ១០៤៧-១០៤៨ និង Redfern Alan, Hunter Martin, Blackaby Niegel, Partasides Constantine. *Redfern and Hunter on International Arbitration*, 6th edition, បោះពុម្ព Oxford University Press ឆ្នាំ២០១៥, ទំព័រ២៥២, កថាខណ្ឌទី៥-៣៩។

[5] Raghavan, Vikram. "Heightened Judicial Review of Arbitral Awards: Perspectives from the UNCITRAL Model Law and the English Arbitration Act of 1996 on some US Developments", *Journal of International Arbitration*, (Kluwer Law International 1998, Vol.15, Issue 3), ទំព័រ១២៧។

ជាបឋម បញ្ហាចម្បងទាក់ទងនឹងការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគឺភាគច្រើនជាទំនាស់នៃការយល់ព្រមរបស់គូភាគីទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មតែម្តង ដោយសារតែការយល់ព្រមរបស់គូភាគីគឺជាធាតុផ្សំសម្រាប់បញ្ជាក់ពីអត្ថិភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម។ ជាពិសេសការយល់ព្រមរបស់គូភាគី គឺជាការបញ្ជាក់អំពីឆន្ទៈរបស់ពួកគេក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការពាណិជ្ជកម្មប្រកបដោយសិទ្ធិនិងកាតព្វកិច្ច ដែលឆ្លុះបញ្ចាំងក្នុងកិច្ចព្រមព្រៀងក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការពាណិជ្ជកម្មស្ថិតនៅក្រោមអនុសញ្ញាមជ្ឈត្តការពាណិជ្ជកម្មជាតិនិងអន្តរជាតិផងដែរ។

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវចែងនូវចំណុចសំខាន់ៗមួយចំនួនដោយរាប់បញ្ចូលដូចជា៖ ទីកន្លែង ឬទីតាំងនៃមជ្ឈត្តការ ស្ថាប័ន ឬវិធានផ្សេងៗត្រូវអនុវត្តចំពោះមជ្ឈត្តការ ចំនួន និងវិធីសាស្ត្រនៃការតែងតាំងមជ្ឈត្តករ វិសាលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ និងភាសាដែលប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ។

ករណីដែលមានអវត្តមាននៃចំណុចសំខាន់ណាមួយ ឬភាពមិនច្បាស់លាស់ណាមួយនៃចំណុចសំខាន់ៗដូចបានរៀបរាប់ គឺមិនមែនជាហេតុធ្វើឲ្យកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអសុពលភាពដោយស្វ័យប្រវត្តិនោះទេ។ ហេតុដូចនេះហើយ ទើបបញ្ហាគតិយុត្តនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចធ្វើការវិនិច្ឆ័យតាមច្រើនរបៀបដូចជា៖ ការវិនិច្ឆ័យទៅលើការយល់ព្រមរវាងគូភាគីក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មផ្ទាល់ ឬតាមរយៈការយល់ព្រមរវាងគូភាគីចំពោះកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិដែលត្រូវបានគ្រប់គ្រងក្រោមប្រព័ន្ធច្បាប់ដែលភាគីបានព្រមព្រៀងគ្នាថានឹងគោរពតាម ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលអាចអនុវត្តបានជាដើម។ ទាក់ទងនឹងការយល់ព្រមរវាងគូភាគីក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មផ្ទាល់គឺបញ្ជាក់បានតាមរយៈភ័ស្តុតាងជាលិខិតទម្រង់សរសេរនិងភ្ជាប់ជាមួយហត្ថលេខារបស់គូភាគី ឬតាមរយៈមធ្យោបាយផ្សេងៗទៀតដោយរួមបញ្ចូលទាំងការសរសេរមិនមែនជាផ្លូវការ ការផ្លាស់ប្តូរលិខិតសរសេរផ្សេងៗ (រាប់ទាំងការផ្លាស់ប្តូរក្នុងប្រព័ន្ធអេឡិចត្រូនិច និងការទំនាក់ទំនងផ្សេងៗទៀត) ទោះបីជាទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលក្តី។ ក្រៅពីនេះ មជ្ឈត្តការពាណិជ្ជកម្មក៏បានជួបប្រទះបញ្ហាទ្រឹស្តីបញ្ហាក្នុងការអនុវត្តជាក់ស្តែងទាក់ទិននឹងជម្រើសនៃច្បាប់ដែលមានអានុភាពអនុវត្តចំពោះកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម។

មុននឹងឈានដល់ការវិនិច្ឆ័យទៅលើសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម យើងតែងតែសង្កេតឃើញអំពីទម្រង់នៃការកកើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងពីរករណី គឺកិច្ចព្រៀមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបែបសរសេរភ្ជាប់នៅក្នុងកិច្ចសន្យាដែលហៅថាខសន្យាមជ្ឈត្តការ(*Arbitration Clause*) និងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបែបមិនសរសេរភ្ជាប់នៅក្នុងកិច្ចសន្យា ដែលហៅថាកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែក(*Arbitration Agreement*)។

ចំពោះករណីកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មស្ថិតក្នុងទម្រង់សរសេរភ្ជាប់ជាមួយកិច្ចសន្យា ជាទូទៅបញ្ហាគតិយុត្តិនៃសុពលភាពកើតមានឡើងនៅពេលដែលកិច្ចសន្យានោះមាននិការៈ។ ហេតុដូច្នេះហើយទើបវាពិតជាមានភាពចាំបាច់ក្នុងការពិចារណាថា តើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវវិនិច្ឆ័យតាមរយៈគោលការណ៍នៃភាពដាច់ចេញពីកិច្ចសន្យាគោល(*Doctrine of Separability*) មុននឹងឈានដល់ការពិនិត្យលើលក្ខខណ្ឌសុពលភាពផ្សេងទៀតនៃកិច្ចព្រមព្រៀងមជ្ឈត្តការ។ ជាបន្ទាប់ ភាពស្មុគស្មាញកើតមានឡើងនៅក្នុងការអនុវត្តគោលការណ៍នៃភាពដាច់ចេញពីកិច្ចសន្យាគោលក្នុងកាលៈទេសៈកិច្ចសន្យាមាននិការៈ ហើយផលវិបាកអាចនឹងកើតមានឡើង ដោយសារតែភាគីណាមួយអាចនឹងបដិសេធថាមិនធ្លាប់មានការបង្កើតកិច្ចសន្យាទាំងមូលឬចំពោះតែផ្នែកកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មប៉ុណ្ណោះ។

ចំណែកឯកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែក គឺមិនទាមទារឲ្យមានការអនុវត្តគោលការណ៍នៃភាពដាច់ចេញពីកិច្ចសន្យាគោល មុននឹងវិនិច្ឆ័យទៅលើបញ្ហាគតិយុត្តនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មទេ ដោយសារតែកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មប្រភេទនេះមិនចែងរួមក្នុងកិច្ចសន្យាគោលឡើយ។

ជំហានបន្ទាប់ គឺជាការវិនិច្ឆ័យលើសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលត្រូវធ្វើការពិនិត្យទាំងលក្ខខណ្ឌទម្រង់និងលក្ខខណ្ឌសារធាតុតាមរយៈច្បាប់ដែលភាគីទាំងអស់ត្រូវតែគោរពតាម ឬច្បាប់ដែលអាចអនុវត្តបានដូចមានចែងក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ពីព្រោះសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការត្រូវបំពេញតាមធាតុផ្សំនៃច្បាប់ដែលគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម។[6]

## ផ្នែកទី១ ច្បាប់ដែលភាគីទាំងអស់ត្រូវគោរពតាម

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវគ្រប់គ្រងដោយច្បាប់ដែលភាគីទាំងអស់បានព្រមព្រៀងគ្នាជ្រើសរើសដើម្បីអនុវត្ត។ ដូច្នេះ ច្បាប់ដែលភាគីព្រមព្រៀងជ្រើសរើសនឹងក្លាយទៅជាច្បាប់ដែលភាគីទាំង អស់ត្រូវគោរពតាមដូចមានចែងក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម។ ប៉ុន្តែនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចមានច្បាប់ចំនួនច្រើន ដែលភាគីបានព្រមព្រៀងជ្រើសរើសក្នុងការគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួនដោយរាប់បញ្ចូលទាំងច្បាប់កិច្ចសន្យាសម្រាប់គ្រប់គ្រងលើកិច្ចសន្យាទាំងមូលឬដោយផ្នែក ឬច្បាប់មជ្ឈត្តការ ឬវិធានមជ្ឈត្តការដែលគ្រប់គ្រងទាំងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក៏ដូចជានីតិវិធីនៃដំណើរការមជ្ឈត្តការផងដែរ។

[6] Mistelis Loukas A. *CISG and Arbitration* រោងពុម្ពCambridge University Press ឆ្នាំ២០១៨, ទំព័រ៣៩៤។

## ១.១. ច្បាប់កិច្ចសន្យា

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវបានគ្រប់គ្រងដោយច្បាប់មជ្ឈត្តការ ឬវិធានមជ្ឈត្តការណាមួយដែលជាលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃមជ្ឈត្តការ។ ប៉ុន្តែនៅពេលដែលមានបញ្ហាគតិយុត្តទាក់ទងនឹងសុពលភាពនៃលក្ខខណ្ឌសារធាតុ(*Substantive Validity*) របស់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មកើតឡើង ច្បាប់កិច្ចសន្យានឹងក្លាយជាមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យដោយផ្ទាល់តែម្តងដោយសារតែវាជាបញ្ហាទាក់ទងនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀងរវាងភាគីដែលបានបង្កើតរួមគ្នា។[7] ប៉ុន្តែច្បាប់កិច្ចសន្យាត្រូវបានបែងចែកចេញជាពីរគឺ ច្បាប់កិច្ចសន្យាអន្តរជាតិនិងច្បាប់កិច្ចសន្យាជាតិដែលមានអានុភាពអនុវត្តនៅពេលដែលភាគីព្រមព្រៀងធ្វើការជ្រើសរើសតាមឆន្ទៈស្ម័គ្រចិត្តសមស្របនឹងស្ថានភាពកិច្ចសន្យាពាណិជ្ជកម្មរបស់ខ្លួន។

### ១.១.១. ច្បាប់កិច្ចសន្យាអន្តរជាតិ

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ(*CISG*) និងគោលការណ៍UNIDROIT នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ(*UPICC*) គឺសុទ្ធតែជាច្បាប់កិច្ចសន្យាអន្តរជាតិដែលគេនិយមប្រើប្រាស់នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មជាសកល។

#### ១.១.១.១. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិបង្កើតឡើងនៅឆ្នាំ១៩៨០ ក្នុងគោលបំណងផ្តល់នូវទំនើបកម្មនូវការអនុវត្តស្របគ្នា និងយុត្តិធម៌សម្រាប់កិច្ចសន្យាលក់ទំនិញអន្តរជាតិដែលអនុវត្តបានចំពោះប្រតិបត្តិការលក់ទំនិញអន្តរជាតិរវាងរដ្ឋជាភាគីនៃអនុសញ្ញាតែប៉ុណ្ណោះ។[8]

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវបានគ្រប់គ្រងដោយអានុភាពនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ក្នុងការបកស្រាយពីឆន្ទៈរបស់ភាគីដែលបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មហើយការបកស្រាយឆន្ទៈរបស់ភាគីគឺជាការវិនិច្ឆ័យតាមរយៈមាត្រាណាមួយនៃមាត្រា ៧, ៨ឬ/និង៩។ ចំពោះបញ្ហាគតិយុត្តនៃការបង្កើតឬទម្រង់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគឺត្រូវវិនិច្ឆ័យតាមផ្នែកទី២នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ដែលមានប្បញ្ញត្តិចាប់ពីមាត្រា១៤ ដល់មាត្រា២៤។

ក៏ប៉ុន្តែ ក្នុងករណីដែលកើតមានបញ្ហាគតិយុត្តទាក់ទងនឹងសុពលភាពនៃលក្ខខណ្ឌសារធាតុរបស់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មវិញ គឺតម្រូវឲ្យមានការវិនិច្ឆ័យដោយផ្អែកទៅលើការពិចារណាតាមរយៈការប្រើ

---

[7] Mistelis Loukas A. *CISG and Arbitration* (រោងពុម្ពCambridge University Press, ឆ្នាំ២០១៤, ទំព័រ៣៩៤។

[8] United Nations Commission on International Trade Law, *United Nations Convention on the International Sale of Goods*, អាចរកបាននៅ https://uncitral.un.org/en/texts/salegoods/conventions/sale_of_goods/cisg (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០២០)។

ប្រាស់កិច្ចសន្យាជាតិរបស់ភាគីណាមួយនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជំនួសវិញ ដោយសារតែផ្នែកទី២ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិមានចែងទាក់ទងនឹងការបង្កើត ឬទម្រង់កិច្ចព្រមព្រៀងតែប៉ុណ្ណោះដូចបានបញ្ជាក់ក្នុងមាត្រា៤(ក)។[9]

### ១.១.១.២. គោលការណ៍UNIDROITនៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ

គោលការណ៍UNIDROITនៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ បានបោះពុម្ពផ្សាយចុងក្រោយបង្អស់ក្នុងឆ្នាំ២០១៦ គឺចងក្រងឡើងដោយមិនមានលក្ខណៈចាប់បង្ខំឲ្យអនុវត្តឬកំណត់ឡើងវិញចំពោះផ្នែកទូទៅនៃច្បាប់កិច្ចសន្យាអន្តរជាតិនោះទេ ប៉ុន្តែគោលការណ៍នេះបានផ្តល់នូវវិធានច្បាប់ប្រកបដោយតុល្យភាពដែលសាកសមជាពិសេសនឹងតម្រូវការនៃការអនុវត្តពាណិជ្ជកម្មអន្តរជាតិទំនើប ហើយត្រូវបានរចនាឡើងសម្រាប់ប្រើប្រាស់នៅទូទាំងពិភពលោក ដោយមិនគិតពីប្រពៃណីនៃច្បាប់ក្នុងស្រុកនិងស្ថានភាពសេដ្ឋកិច្ចនិងនយោបាយនៃប្រទេសដែលពួកគេត្រូវអនុវត្តនោះឡើយ។[10]

រាល់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ដែលស្ថិតក្រោមអានុភាពនៃការគ្រប់គ្រងរបស់គោលការណ៍ UNIDROIT នៅពេលបញ្ហាគតិយុត្តទាក់ទងនឹងសុពលភាពទម្រង់ឬលក្ខខណ្ឌសារជាតុនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មកើតមានឡើង គឺទាមទារឲ្យមានការពិនិត្យថាតើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានចំណុចឬអត្ថន័យផ្ទុយនឹងបញ្ញត្តិណាមួយក្នុងជំពូកទី២ ផ្នែកទី១(ការបង្កើត)ឬជំពូកទី៣សុពលភាពនៃគោលការណ៍ UNIDROIT ដែរឬទេ។ ម៉្យាងទៀត ប្រសិនជាមានអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មពិតប្រាកដមែន ភាគីនៃកិច្ចព្រមព្រៀងអាចផ្អែកលើមាត្រាណាមួយក្នុងចំណោមមូលដ្ឋាននៃមោឃៈភាពកិច្ចសន្យានៅក្នុងជំពូកទី៣ ផ្នែកទី២នៃគោលការណ៍ UNIDROIT នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិដើម្បីមិនអនុវត្តកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលមិនមានសុពលភាពនោះបាន។

### ១.១.២. ច្បាប់កិច្ចសន្យាជាតិ

ច្បាប់កិច្ចសន្យាជាតិ គឺជាច្បាប់គ្រប់គ្រងនូវកិច្ចសន្យាទាំងឡាយដែលបង្កើតឡើងនៅក្នុងឬមានទំនាក់ទំនងនឹងយុត្តាធិការច្បាប់នៃរដ្ឋជាក់លាក់ណាមួយ។ យោងតាមវិសាលភាពនៃការប្រធានបទនេះ ច្បាប់កិច្ចសន្យាជាតិនឹងធ្វើការផ្តោតសំខាន់ទៅលើការបកស្រាយចំពោះតែច្បាប់កិច្ចសន្យានៃប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីតែប៉ុណ្ណោះ។

---

[9] United Nations Commission on International Trade Law, *UNCITRAL Digest of Case Law on the United Nations Convention on the International Sale of Goods*, ឆ្នាំ២០១២, ទំព័រទី២៥, កថាខណ្ឌទី១៤។

[10] UNIDROIT Secretariat, *UNIDROIT Work and Instruments in the area of Contract Law*, អាចរកបាននៅ https://www.unidroit.org/contracts (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០២០)។

### ១.១.២.១. ក្រមរដ្ឋប្បវេណីកម្ពុជា

នៅក្នុងប្រទេសកម្ពុជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា( Civil Code of Cambodia 2007) គឺមានចែងទាក់ទងនឹងការគ្រប់គ្រងកិច្ចសន្យា ដោយសារតែប្រទេសកម្ពុជាមិនទាន់មាននូវច្បាប់ពិសេសសម្រាប់គ្រប់គ្រងកិច្ចសន្យានៅឡើយទេ។ ជាគោលការណ៍កិច្ចសន្យាឬកិច្ចព្រមព្រៀងត្រូវធ្វើឡើងដោយសេរីតាមរយៈសំណើនិងស្វីការត្រូវគ្នា។ [11] ទន្ទឹមនឹងនេះ ភាគីដែលបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការក៏តម្រូវឲ្យមានសមត្ថភាពក្នុងការចុះកិច្ចព្រមព្រៀងមជ្ឈត្តការនេះដែរ ដោយភាគីត្រូវមានសមត្ថភាពក្នុងការសម្តែងឆន្ទៈនិងមានសមត្ថភាពក្នុងការធ្វើសកម្មភាពដូចដែលច្បាប់បានកំណត់។ មានន័យថា ពេលភាគីបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការគឺភាគីត្រូវស្ថិតនៅក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹង និងអាចវិនិច្ឆ័យអំពីលទ្ធផលផ្លូវច្បាប់នៃការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការ។[12]

ក្រមរដ្ឋប្បវេណី គន្ថីទី៤ ជំពូកទី២ ផ្នែកទី២ គឺជាបញ្ញត្តិច្បាប់ដែលចែងអំពីសុពលភាពនៃកិច្ចសន្យាដូចនេះដើម្បីបង្កើតកិច្ចសន្យាមួយឲ្យមានសុពលភាព គឺទាមទារឲ្យមានសេរីភាពក្នុងការបង្ហាញឆន្ទៈពិតប្រាកដនិងដោយស្ម័គ្រចិត្តពីសំណាក់ភាគីនៃកិច្ចសន្យាទើបការវិនិច្ឆ័យទៅលើការបង្ហាញឆន្ទៈពិតជាមានសារៈសំខាន់ដើម្បីបញ្ជាក់ពីសុពលភាពនៃកិច្ចសន្យា។ ម៉្យាងវិញទៀត អត្ថន័យនិងកម្មវត្ថុនៃកិច្ចសន្យាក៏មិនត្រូវចែងខុសពីប្បញ្ញត្តិច្បាប់កំណត់នោះទេដូចជា៖ កិច្ចសន្យាទាក់ទងនឹងការបែងចែកនៃការលក់ទំនិញគេចពន្ធឬកិច្ចសន្យាទាក់ទងនឹងការទំនិញដោយប្រកួតប្រជែងមិនស្មោះត្រង់ជាដើម។

យោងតាមមាត្រា៣៤៥នៃក្រមរដ្ឋប្បវេណី អ្នកដែលបង្ហាញឆន្ទៈអាចមោឃៈ ឬលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈរបស់ភាគីនៃកិច្ចសន្យាមានវិការៈឬកិច្ចសន្យា ដែលបានបង្កើតឡើងមានខ្លឹមសារខុសច្បាប់ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈឬទំនៀមទម្លាប់ល្អ។ វិការៈនៃការបង្ហាញឆន្ទៈ គឺកើតមានឡើងដូចជាតាមរយៈការបង្ហាញឆន្ទៈដោយភាន់ច្រឡំ[13] ការបង្ហាញឆន្ទៈដោយការឆបោក[14] ការបង្ហាញឆន្ទៈដោយទទួលបានពត៌មានមិនពិត [15] ការបង្ហាញឆន្ទៈដោយមានការរំលោភលើស្ថានភាព [16] ការបង្ហាញឆន្ទៈដោយមានការ

[11] មាត្រា៣៣៦ និងមាត្រា៣៣៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[12] មាត្រា១៥ និងមាត្រា១៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[13] មាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[14] មាត្រា៣៤៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[15] មាត្រា៣៤៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[16] មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

គម្រាមកំហែង[17] ការបង្ហាញឆន្ទៈដោយមានការកេងចំណេញហួសហេតុ[18] បបនីយផ្លូវចិត្ត[19] និងការបង្ហាញឆន្ទៈមិនពិត[20]។

ការបង្ហាញឆន្ទៈដោយភាន់ច្រឡំ គឺកើតតាមរយៈអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយយល់ឃើញខុសពីការពិតជាក់ស្តែង និងមិនបានដឹងថាការយល់ឃើញរបស់ខ្លួនខុសពីការពិតជាក់ស្តែងដែលកើតចេញពីការយល់ឃើញដោយខ្លួនឯង។ យោងតាមមាត្រា៣៤៦នៃក្រមរដ្ឋប្បវេណី ការបង្ហាញឆន្ទៈដោយការភាន់ច្រឡំមានបែងចែកជាបីករណីគឺការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា[21] ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី[22] និងការភាន់ច្រឡំរួមគ្នា[23]។

ការបង្ហាញឆន្ទៈដោយការឆបោក កើតចេញពីអ្នកបង្ហាញឆន្ទៈយល់ឃើញខុសពីការពិតជាក់ស្តែងហើយមិនបានដឹងថាការយល់ឃើញរបស់ខ្លួនគឺខុសពីការពិតជាក់ស្តែងទេ។ លើសពីនេះទៅទៀត ការយល់ឃើញដែលខុសពីការពិតជាក់ស្តែងនេះ គឺកើតមានឡើងដោយសារតែអ្នកបង្ហាញឆន្ទៈបានទទួលនូវព័ត៌មានក្លែងក្លាយពីអ្នកដទៃហើយអ្នកផ្តល់ព័ត៌មានក្លែងក្លាយនោះមានចេតនាកុហកបោកប្រាស់ឬប្រើកលល្បិច។ យោងតាមមាត្រា៣៤៧នៃក្រមរដ្ឋប្បវេណី ការបង្ហាញឆន្ទៈដោយការឆបោកមានបែងចែកជាពីរករណីគឺការឆបោកដោយភាគី[24] និងការឆបោកដោយតតិយជន[25]។

ការបង្ហាញឆន្ទៈដោយទទួលបានព័ត៌មានមិនពិត គឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាងដោយយល់ខុស ពីការពិតជាក់ស្តែងហើយគាត់មិនបានដឹងថាការយល់ឃើញរបស់ខ្លួនខុសពីការពិតជាក់ស្តែងទេ ដោយសារ គាត់ទទួលបានព័ត៌មានមិនពិតដោយសុចរិតពីភាគីម្ខាងទៀត។ មានន័យថាអ្នកផ្តល់ព័ត៌មានមិនពិតមិនមាន ចេតនាកុហកបោកប្រាស់ឬក្លែងបន្លំអ្នកបង្ហាញឆន្ទៈឡើយ។

ការបង្ហាញឆន្ទៈដោយមានការរំលោភលើស្ថានភាព គឺអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយមានការភ័យខ្លាចនិងមិនអាចតបតវិញបាន ដោយសារតែភាគីម្ខាងទៀតប្រើប្រាស់នូវឋានៈឬស្ថានភាពអាទិភាពរបស់ខ្លួនដោយមិនត្រឹមត្រូវនិងជាសម្ពាធក្នុងពេលបង្កើតកិច្ចសន្យា។

[17] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[18] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[19] មាត្រា៣៥២ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[20] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[21] មាត្រា៣៤៦(១) នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[22] មាត្រា៣៤៦(២) នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[23] មាត្រា៣៤៦(៣) នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[24] មាត្រា៣៤៧(១) នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។
[25] មាត្រា៣៤៧(២) នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស/ រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

ការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែង កើតឡើងនៅពេលដែលអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយសារតែការគម្រាមកំហែងពីភាគីម្ខាងទៀតតាមរយៈពាក្យសម្ដីឬកាយវិការក្នុងគោលដៅឲ្យអ្នកបង្ហាញឆន្ទៈភ័យខ្លាច។ ទង្វើនៃការគម្រាមកំហែងអាចធ្វើចំពោះអ្នកបង្ហាញឆន្ទៈផ្ទាល់ឬចំពោះសាច់ញាតិអ្នកបង្ហាញឆន្ទៈហើយការគម្រាមកំហែងនេះអាចប្រព្រឹត្តឡើងដោយភាគីផ្ទាល់ឬដោយតតិយជន។

ការបង្ហាញឆន្ទៈដោយមានការកេងចំណេញហួសហេតុ កើតឡើងពីការបង្ហាញឆន្ទៈរបស់ភាគីក្នុងស្ថានភាពដែលខ្លួនកំពុងជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ចឬភាពល្ងង់ឬខ្វះបទពិសោធន៍។ ប៉ុន្តែអ្នកបង្ហាញឆន្ទៈត្រូវធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនដោយមិនមានការភ័យខ្លាចឡើយ។ ចំណែកឯភាគីម្ខាងទៀត គឺមានចេតនាក្នុងការឆ្លៀតឱកាសបង្កើតកិច្ចសន្យាដោយកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ក្នុងស្ថានភាពបែបនេះ។

បបនីយផ្លូវចិត្ត មានន័យថាអ្នកបង្ហាញឆន្ទៈដឹងខ្លួនថាបានបង្ហាញឆន្ទៈរបស់ខ្លួនដោយឋបនីយព្រោះការបង្ហាញឆន្ទៈនេះខុសពីការពិត ហើយភាគីម្ខាងទៀតក៏បានដឹងអំពីការបង្ហាញឆន្ទៈក្នុងស្ថានភាពឋបនីយផ្លូវចិត្តផងដែរ។

ចំពោះការបង្ហាញឆន្ទៈមិនពិតវិញ គឺកើតចេញពីភាគីនៃកិច្ចសន្យាបានឃុបឃិតគ្នាក្នុងការបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់ខ្លួន។

សរុបជារួម ភាគីបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលកិច្ចសន្យាបាន ក្នុងករណីការបង្ហាញឆន្ទៈកើតមានឡើងដោយការភាន់ច្រឡំ ការបង្ហាញឆន្ទៈដោយការឆបោក ការបង្ហាញឆន្ទៈដោយទទួលបានព័ត៌មានមិនពិត ការបង្ហាញឆន្ទៈដោយមានការរំលោភលើស្ថានភាព ការបង្ហាញឆន្ទៈដោយមានការគម្រាមកំហែង និងការបង្ហាញឆន្ទៈដោយមានការកេងចំណេញហួសហេតុ។ ចំពោះភាគីបង្ហាញឆន្ទៈដែលមានវិការៈក្នុងករណីឋបនីយផ្លូវចិត្តវិញ គឺអាចទាមទារការបដិសេធការអនុវត្តបាន។ ចំណែកឯភាគីបង្ហាញឆន្ទៈដែលមានវិការៈក្នុងករណីការបង្ហាញឆន្ទៈមិនពិត គឺអាចទាមទារឲ្យកិច្ចសន្យាចាត់ទុកជាមោឃៈបាន។

ចំណែកឯភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អក្នុងអត្ថន័យកិច្ចសន្យាគឺជាកត្តាមួយដែលធ្វើឲ្យកិច្ចសន្យាអសុពលភាពដូចគ្នា។ ហេតុដូចនេះហើយទើបកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ[26] ក្នុងករណីខ្លឹមសារនៃកិច្ចសន្យាខុសទៅនឹងអ្វីដែលច្បាប់បានហាមឃាត់ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ។

### ១.១.២.២. ច្បាប់ស្ដីពីកិច្ចសន្យាម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីបានបង្កើតច្បាប់ស្ដីពីកិច្ចសន្យាម៉ាឡេស៊ីឆ្នាំ១៩៥០(Malaysia Contract Act 1950) សម្រាប់គ្រប់គ្រងកិច្ចសន្យាទាំងឡាយ ដែលមានទំនាក់ទំនងជាមួយនឹងយុត្តាធិការរបស់ម៉ាឡេស៊ីឬក៏បង្កើត

[26] មាត្រា៣៥៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

ឡើងនៅក្នុងដែនដីនៃប្រទេសម៉ាឡេស៊ីផ្ទាល់។ ជាក់ស្តែង ច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ីត្រូវបានធ្វើវិសោធនកម្មច្រើនដងរួចមកហើយ ដើម្បីឲ្យសមស្របនឹងការអភិវឌ្ឍន៍របស់សង្គមម៉ាឡេស៊ីទាក់ទងនឹងកិច្ចសន្យា។ នៅក្នុងបរិបទច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី រាល់កិច្ចព្រមព្រៀងទាំងឡាយត្រូវបានចាត់ទុកជាកិច្ចសន្យាប្រសិនបើបានបង្កើតឡើងដោយមានការព្រមព្រៀងស្ម័គ្រចិត្តរបស់ភាគី ដែលមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាទាក់ទងនឹងតម្លៃតបស្នងស្របតាមច្បាប់កំណត់និងមានគោលបំណងស្របច្បាប់ផងដែរ ដោយរួមផ្សំទាំងមិនមានការប្រកាសថាត្រូវទុកជាមោឃៈ។ [27] គួរឲ្យកត់សម្គាល់ផងដែរថាច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ីក៏បានចែងអំពីការសង្គ្រោះកិច្ចសន្យាដែលសំដៅទៅលើវិវាទមជ្ឈត្តការមិនត្រូវចាត់ទុកជាមោឃៈឡើយ ទោះបីវាជាប្រភេទកិច្ចសន្យាដែលមានការរារាំងដំណើរការតាមផ្លូវច្បាប់ផ្នែកសាលាក្តីសាមញ្ញក៏ដោយ ។ យោងតាមមាត្រា២៨នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី ការសង្គ្រោះកិច្ចសន្យាដែលសំដៅទៅលើការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការអាចធ្វើឡើងតាមករណីលើកលែង២ប្រភេទ។

ករណីលើកលែងទី១ ទាក់ទងនឹងការសង្គ្រោះកិច្ចសន្យាដែលសំដៅទៅលើវិវាទនៅឯមជ្ឈត្តការដែលអាចកើតមានឡើង។ កិច្ចព្រមព្រៀងមជ្ឈត្តការមិនត្រូវចាត់ទុកជាកិច្ចសន្យាខុសច្បាប់នោះទេ ទោះបីជាមានមនុស្ស ពីរនាក់ ឬច្រើននាក់ យល់ស្របកំណត់ថាវិវាទណាមួយនឹងអាចកើតឡើងរវាងពួកគេទាក់ទងនឹងកម្មវត្ថុ ឬប្រភេទណាមួយនៃកម្មវត្ថុដែលត្រូវបញ្ជូនទៅមជ្ឈត្តការដើម្បីដោះស្រាយ ហើយមានតែទំហំដែលទទួលបានតាមរយៈការកំណត់នៅក្នុងសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសប៉ុណ្ណោះទើបអាចសង្គ្រោះវិវាទដែលបានបញ្ជូនមកនោះបាន។

ករណីលើកលែងទី២ ទាក់ទងនឹងការសង្គ្រោះកិច្ចសន្យាដែលសំដៅទៅលើបញ្ហាដែលបានកើតឡើងរួចមកហើយ។ កិច្ចព្រមព្រៀងមជ្ឈត្តការមិនត្រូវចាត់ទុកជាកិច្ចសន្យាសរសេរដែលខុសច្បាប់ទេ ទោះបីជាបង្កើតឡើងរវាងមនុស្សពីរនាក់ឬច្រើននាក់អំពីការយល់ព្រមបញ្ជូនទៅមជ្ឈត្តការនូវបញ្ហានានា ដែលបានកំណត់ទុកឬជាបញ្ហាដែលកើតឡើងរួចមកហើយ ឬជាការប៉ះពាល់ដល់ច្បាប់ណាមួយដែលទាក់ទងនឹងមជ្ឈត្តការ។ ទោះជាយ៉ាងណាក្តី អសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនឹងកើតមានឡើងប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបង្កើតឡើង ដោយមានផលនៃតម្លៃតបស្នងនិងគោលបំណងផ្ទុយនឹងបញ្ញត្តិច្បាប់នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី។ [28] គ្រប់ផលនៃតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងគឺតម្រូវឲ្យត្រឹមត្រូវស្របតាមច្បាប់កំណត់ លុះត្រាតែផលនៃតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងត្រូវបានហាមឃាត់ដោយ

[27] ផ្នែកទី១០(១) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[28] ផ្នែកទី២៥ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

ច្បាប់ [29] កត្តាធម្មជាតិរបស់ផលនៃតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងនឹងធ្វើឲ្យកើតមាននូវឥទ្ធិពលអាក្រក់ដល់ច្បាប់ [30] ផលនៃតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងកើតពីការបន្លំ [31] ការបង្កើតផលនៃតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងដោយជាប់ទាក់ទង ឬមានការបង្ករបួសស្នាមដល់បុគ្គល ឬទ្រព្យសម្បត្តិភាគីណាមួយនៃកិច្ចព្រមព្រៀង [32] ឬនៅពេលដែលតុលាការចាត់ទុកថាតម្លៃតបស្នងនិងគោលបំណងនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មប៉ះពាល់ដល់សីលធម៌ឬប្រឆាំងនឹងសណ្តាប់ធ្នាប់សាធារណៈ[33]។

ជាទូទៅ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវបង្កើតឡើងដោយត្រូវគោរពលក្ខខណ្ឌនៃកិច្ចសន្យាធម្មតាដូចគ្នាគឺភាគីនៃកិច្ចព្រមព្រៀងត្រូវតែជាបុគ្គលមានសមត្ថភាពធ្វើកិច្ចសន្យា ដែលតម្រូវឲ្យមានអាយុច្រើនបំផុតស្របតាមនីតិភាពនៃច្បាប់ដែលខ្លួនត្រូវគោរពប្រកបដោយស្មារតីល្អ និងមិនមានការដកហូតសិទ្ធិទាក់ទងនឹងការធ្វើកិច្ចសន្យាពីច្បាប់ណាមួយដែលខ្លួនជាកម្មវត្ថុនៃអានុភាពនោះទេ។[34] បន្ថែមពីនេះទៀត បុគ្គលដែលមានស្មារតីល្អ គឺសំដៅទៅលើបុគ្គលអាចពិចារណានិងយល់ដឹងអំពីលទ្ធផលផ្លូវច្បាប់ដែលខ្លួននឹងទទួលបាននូវពេលដែលខ្លួនបង្កើតកិច្ចសន្យាជាមួយភាគីម្ខាងទៀត។ [35] ចំពោះបរិបទច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ីករណីដែលភាគីគួរជៀសវាងបន្ថែមដើម្បីកុំឲ្យកើតមាននូវអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម គឺត្រូវធ្វើឡើងដោយមានការយល់ព្រមដោយស្ម័គ្រចិត្ត [36] ដែលជាការយល់ព្រមដោយគ្មានការបង្ខិតបង្ខំ [37] ការស្ថិតនៅក្រោមឥទ្ធិពល[38] ការឆបោក[39] ការបង្ហាញខុស[40] ឬកំហុស[41]។

ការយល់ព្រមដោយស្ម័គ្រចិត្តគឺជាការយល់ព្រមដោយសេរីដែលមិនមែនកើតមានឡើង ដោយសារតែស្ថានភាពនៃការបង្ខិតបង្ខំ ការស្ថិតនៅក្រោមឥទ្ធិពល ការឆបោក ការបង្ហាញខុស និងកំហុសនោះទេ។[42]

---

[29] ផ្នែកទី២៤(ក) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[30] ផ្នែកទី២៤(ខ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[31] ផ្នែកទី២៤(គ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[32] ផ្នែកទី២៤(ឃ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[33] ផ្នែកទី២៤(ង) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[34] ផ្នែកទី១១ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[35] ផ្នែកទី១២ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[36] ផ្នែកទី១៤ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[37] ផ្នែកទី១៥ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[38] ផ្នែកទី១៦ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[39] ផ្នែកទី១៧ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[40] ផ្នែកទី១៨ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[41] ផ្នែកទី២១, ២២ និង២៣ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[42] ផ្នែកទី១៤ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

ការបង្ខិតបង្ខំ គឺជាការប្រព្រឹត្តឬការគំរាមធ្វើនូវរាល់សកម្មភាពដែលហាមឃាត់ដោយក្រមព្រហ្មទណ្ឌ ឬការឃុំខ្លួនដោយខុសច្បាប់ ឬការគំរាមកំហែងអំពីការឃុំខ្លួន ឬការគំរាមកំហែងទាក់ទងនឹងទ្រព្យសម្បត្តិណាមួយ ការរើសអើងបុគ្គលណាមួយជាចេតនាធ្វើឲ្យបុគ្គលណាមួយយល់ព្រមបង្កើតកិច្ចព្រមព្រៀងឡើង។[43]

ការស្ថិតនៅក្រោមឥទ្ធិពល គឺជាស្ថានភាពនៃការបង្កើតកិច្ចសន្យាដែលបានភ្ជាប់នូវទំនាក់ទំនងរវាងភាគីនៃកិច្ចសន្យា ដោយភាគីម្ខាងមានឋានៈអាចត្រួតត្រាលើឆន្ទៈរបស់ភាគីម្ខាងទៀតហើយភាគីម្ខាងដែលមានឋានៈនោះក៏បានប្រើប្រាស់នូវឋានៈរបស់ខ្លួន ដើម្បីកេងចំណេញនិងទទួលបានអត្ថប្រយោជន៍ច្រើនជាងភាគីម្ខាងទៀត ។[44] ការវិនិច្ឆ័យចំពោះបុគ្គលដែលចាត់ទុកថាមានឋានៈអាចត្រួតត្រាលើឆន្ទៈរបស់បុគ្គលដទៃបានមានពីរករណី គឺ៖ (១)ការកើតឡើងពេលដែលបុគ្គលម្នាក់បានកាន់កាប់នូវអំណាចពិតប្រាកដឬជាក់ស្តែងទៅលើបុគ្គលម្នាក់ ទៀតឬជាការកើតឡើងនៅពេលដែលបុគ្គលម្នាក់បានស្ថិតនៅក្នុងទំនាក់ទំនងនៃការទុកចិត្តពីបុគ្គលម្នាក់ទៀត[45] ឬ (២)ការកើតឡើងនៅពេលបុគ្គលណាម្នាក់បានបង្កើតកិច្ចសន្យាជាមួយបុគ្គលម្នាក់ទៀតដែលមានបញ្ហាស្មារតីជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ដោយសារតែកត្តាអាយុ ជម្ងឺ ឬបញ្ហាផ្លូវអារម្មណ៍ ឬផ្លូវកាយ[46]។ លើសពីនេះទៅទៀត ការស្ថិតនៅក្រោមឥទ្ធិពលក៏អាចកើតមាននៅពេលដែលបុគ្គលណាម្នាក់ស្ថិតនៅក្នុងឋានៈជាអ្នកមានអំណាចត្រួតត្រាលើឆន្ទៈអ្នកដទៃ ជាហេតុធ្វើឲ្យអ្នកដទៃចុះកិច្ចសន្យាជាមួយខ្លួននិងលេចនូវរូបរាងប្រតិបត្តិការកើតឡើងនៅចំពោះមុខ ឬជាភ័ស្តុតាងដែលបង្ហាញឡើងក្នុងទម្រង់ជាការបង្កើតដោយមិនបានពិចារណាជាបន្ទុកក្នុងការបង្ហាញថា កិច្ចសន្យាមិនត្រូវបានបង្កើតឡើងក្រោមឥទ្ធិពលនៃការកុហករបស់បុគ្គលដែលស្ថិតក្នុងឋានៈជាអ្នកត្រួតត្រាលើឆន្ទៈអ្នកដទៃ។[47]

ការឆបោក គឺរួមបញ្ចូលនូវសកម្មភាពទាំងឡាយណាដែលបានប្រព្រឹត្តដោយភាគីណាមួយនៃកិច្ចសន្យា ឬដោយភាពប្រាកដប្រជារបស់ខ្លួន ឬដោយភ្នាក់ងាររបស់ខ្លួនក្នុងគោលបំណងបោកបញ្ឆោតភាគីម្ខាងទៀតឬភ្នាក់ងារម្ខាង ឬដើម្បីជំរុញឲ្យភាគីម្ខាងទៀតបង្កើតកិច្ចសន្យាតាមរយៈការផ្តល់យោបល់ជាអង្គហេតុដែលមិនពិតដោយបុគ្គលដែលមិនជឿថាវាជាការពិត [48] ការលាក់បាំងយ៉ាងសកម្មចំពោះអង្គហេតុដោយបុគ្គលដែលមានចំ-

[43] ផ្នែកទី១៥ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[44] ផ្នែកទី១៦(១) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[45] ផ្នែកទី១៦(១)(ក) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[46] ផ្នែកទី១៦(១)(ខ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[47] ផ្នែកទី១៦(៣)(ក) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[48] ផ្នែកទី១៧(ក) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

ណេះដឹងឬមានជំនឿលើអង្គហេតុ [49] ការសន្យាដែលបង្កើតឡើងដោយមិនមានចេតនាក្នុងការប្រតិបត្តិតាម [50] សកម្មភាពផ្សេងទៀតដែលត្រូវបានធ្វើឡើងដើម្បីជាការបញ្ឆោត [51] និងរាល់ទង្វើសកម្មឬអកម្មទាំងឡាយដែលច្បាប់បានកំណត់ជាពិសេសថាជាការក្លែងបន្លំ[52]។

ការបង្ហាញខុសគឺរួមបញ្ចូលនូវសកម្មភាពដូចជា៖ ការអះអាងវិជ្ជមានក្នុងលក្ខណៈដែលមិនត្រូវបានការពារដោយព័ត៌មានរបស់បុគ្គលដែលបង្កើតវាជារឿងមិនពិត ទោះបីជាបុគ្គលនោះជឿជាក់ថាវាជាការពិតក៏ដោយ[53] ការបំពានលើកាតព្វកិច្ចណាមួយដោយមិនមានចេតនាបោកបញ្ឆោតផ្តល់ផលប្រយោជន៍ដល់បុគ្គល ដែលប្រព្រឹត្ត ឬនរណាម្នាក់ដែលអះអាងស្ថិតនៅក្រោមខ្លួនដោយបំភាន់អ្នកដទៃចំពោះការរើសអើងរបស់ខ្លួន ឬការរើសអើងរបស់នរណាម្នាក់ដែលអះអាងស្ថិតនៅក្រោមខ្លួន [54] និងទោះបីជាការបង្កឡើងស្ថិតនៅក្នុងភាពគ្មានកំហុសភាគីនៃកិច្ចព្រមព្រៀងបង្កើតកំហុសដែលជាខ្លឹមសារនៃវត្ថុដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង[55]។

ចំពោះកំហុសមានបែងចែកចេញជាបីស្ថានភាពដូចជា៖ កំហុសនៃអង្គហេតុដែលអង្គហេតុនោះគឺជាភាពចាំបាច់ចំពោះការបង្កើតកិច្ចសន្យាឬកិច្ចព្រមព្រៀង [56] កំហុសនៃអង្គច្បាប់ដែលចូលជាធរមាននៅក្នុងប្រទេសម៉ាឡេស៊ី ប៉ុន្តែក្នុងករណីដែលកំហុសនៃអង្គច្បាប់ដែលមិនបានចូលជាធរមាននៅក្នុងប្រទេសម៉ាឡេស៊ីគឺត្រូវចាត់ទុកដូចជាករណីកំហុសនៃអង្គហេតុវិញ[57] កំហុសរបស់ភាគីណាមួយដែលជាបញ្ហានៃអង្គហេតុ[58]។

## ១.២. ច្បាប់មជ្ឈត្តការពាណិជ្ជកម្ម

ទោះបីជា កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មតម្រូវឲ្យមានការបង្កើតឡើងដោយមិនផ្ទុយនឹងបញ្ញត្តិនៃច្បាប់ដែលភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជ្រើសរើសក៏ដោយ ប៉ុន្តែកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក៏នៅតែតម្រូវឲ្យមានការបង្កើតឡើងឲ្យស្របនឹងលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌសារធាតុដែលមិនផ្ទុយនឹងបញ្ញត្តិនៃច្បាប់មជ្ឈត្តការដែលភាគីព្រមព្រៀងគ្នា។ បណ្តាប្រទេសជាច្រើននៅក្នុងសកលលោកយើងបានបង្កើតច្បាប់មជ្ឈត្តការដែលផ្តល់ជូននូវក្របខណ្ឌច្បាប់សម្រាប់ដំណើរការមជ្ឈត្តការក្នុងយុត្តាធិការរបស់ខ្លួនផងដែរ។

---

[49] ផ្នែកទី១៧(ខ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[50] ផ្នែកទី១៧(គ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[51] ផ្នែកទី១៧(ឃ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[52] ផ្នែកទី១៧(ង) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[53] ផ្នែកទី១៨(ក) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[54] ផ្នែកទី១៨(ខ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[55] ផ្នែកទី១៨(គ) នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[56] ផ្នែកទី២១ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[57] ផ្នែកទី២២ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[58] ផ្នែកទី២៣ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

ជាទូទៅប្រទេសជាច្រើន បង្កើតច្បាប់មជ្ឈត្តការរបស់ខ្លួនដោយផ្អែកទៅលើគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ( *UNCITRAL Model Law on International Commercial Arbitration*) ដោយសារតែគម្រូច្បាប់នេះឆ្លុះបញ្ចាំងពីការមូលមតិគ្នាដោយឯកច្ឆ័នជាសកលទៅលើគន្លឹះទិដ្ឋភាពសំខាន់ៗ នៃការអនុវត្តមជ្ឈត្តការអន្តរជាតិដែលត្រូវបានយល់ព្រមទទួលយកដោយរដ្ឋគ្រប់តំបន់ទាំងអស់នៅលើពិភពលោក ទោះបីជារដ្ឋទាំងនោះមានប្រព័ន្ធច្បាប់ខុសគ្នាឬសេដ្ឋកិច្ចខុសគ្នាក៏ដោយ។ គម្រូច្បាប់នេះបានបង្កើតដំបូងនៅឆ្នាំ១៩៨៥ ប៉ុន្តែគម្រូច្បាប់នេះត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៦ ដើម្បីចែងបន្ថែមនៅចំណុចខ្វះខាតមួយចំនួន ដើម្បីសម្របតាមតម្រូវនាសម័យទំនើប។ គម្រូច្បាប់ត្រូវអនុវត្តក្នុងករណីភាគីនៃវិវាទបានព្រមព្រៀងដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមរយៈមជ្ឈត្តកម្មដោយស្ថិតក្រោមការគ្រប់គ្រងរបស់វិធាននៃមជ្ឈត្តការណាមួយ ឬប្រសិនបើភាគីបានព្រៀមព្រៀងក្នុងពាក្យពេជន៍ផ្សេងទៀតដែលមានអត្ថន័យដូចគ្នា។ គម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការអង្គការសហប្រជាជាតិនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិ។

គួរបញ្ជាក់ផងដែរថា គម្រូច្បាប់មានចែងគ្រប់ដំណាក់កាលនៃដំណើរការមជ្ឈត្តការដោយរាប់បញ្ចូលទាំងពេលចាប់ផ្ដើមបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ចាប់ផ្ដើមបង្កើតសមាសភាពនៃវេទិកាមជ្ឈត្តកម្មសមត្ថកិច្ចនៃវេទិកាមជ្ឈត្តកម្ម វិសាលភាពនៃការអន្តរាគមន៍របស់តុលាការរហូតដល់ការទទួលស្គាល់និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេសហើយការបង្កើតនេះ គឺជាជំនួយនៃកំណែទម្រង់និងទំនើបកម្មច្បាប់នីតិវិធីមជ្ឈត្តការរបស់បណ្ដាប្រទេសនានាលើពិភពលោក ដើម្បីពិចារណាលើលក្ខណៈពិសេសនិងតម្រូវការនៃមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ។[59]

ទាក់ទងទៅនឹងទម្រង់នៃកិច្ចព្រមព្រៀងមជ្ឈត្តការ UNCITRAL បានផ្ដល់ជម្រើសពីរប្រភេទនៅក្នុងគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ដែលមានលក្ខណៈពិសេសខុសពីច្បាប់ដទៃទៀតត្រង់ចំណុចកិច្ចព្រមព្រៀងមជ្ឈត្តការនៅតែមានសុពលភាពទោះបីជាស្ថិតនៅក្នុងទម្រង់សរសេរ ឬមិនសរសេរក៏ដោយ។[60]

ចំពោះទម្រង់សរសេរ គឺភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួនជាលក្ខណៈសរសេរក្នុងទម្រង់ណាមួយក៏បាន ដែលវាអាចជាការកត់ត្រាក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកឬក្នុងខសន្យាមជ្ឈត្តការ ឬតាមរយៈមធ្យោបាយផ្សេងៗទៀត។[61]

---

[59] United Nations Commission on International Trade Law, *International Commercial Arbitration*, អាចរកបាននៅ https://uncitral.un.org/en/texts/arbitration/modellaw/commercial_arbitration (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០២០)។

[60] ជម្រើសទី១ និងជម្រើសទី២-មាត្រា៧នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ, ១៩៨៥(វិសោធនកម្ម២០០៦)។។

[61] ជម្រើសទី១-មាត្រា៧នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ,១៩៨៥។

នៅក្នុងឆ្នាំ២០០៦ គម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិបានធ្វើវិសោធនកម្មបន្ថែមនូវជម្រើសទាក់ទងនឹងទម្រង់មិនសរសេរនៃកិច្ចព្រមព្រៀងមជ្ឈត្តការ។[62] ទម្រង់មិនសរសេរគឺសំដៅទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មទាំងឡាយដែលបង្កើតឡើងក្នុងទម្រង់បែបណាក៏បាន ដរាបណាខ្លឹមសារនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចរក្សាទុកជាភស្តុតាងបាន។ ដោយសារតែស្ថិតក្នុងយុគ្គសម័យកាលទំនើប កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មលែងត្រូវការហត្ថលេខារបស់ភាគី ឬការផ្លាស់ប្តូរលិខិតគ្នារវាងភាគីដើម្បីបញ្ជាក់ពីឆន្ទៈក្នុងការដាក់វិវាទដោះស្រាយនៅមជ្ឈត្តការពាណិជ្ជកម្មទៀតឡើយ។ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបានធ្វើទំនើបកម្មក្នុងការបញ្ជាក់ពីឆន្ទៈរបស់ភាគីយល់ព្រមចំពោះការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម តាមរយៈប្រព័ន្ធអេឡិចត្រូនិចដោយសារតែមានភាពរហ័ស ចំណាយតិចនិងមានភាពងាយស្រួល។

លើសពីនេះទៅទៀត កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនឹងក្លាយជាអសុពល ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនោះមានចែងអ្វីបំពាន ឬផ្ទុយនឹងបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំនៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្ម ដោយសារតែមូលហេតុថាបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំនៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មគឺជាមូលដ្ឋានលក្ខខណ្ឌចាំបាច់ធម្មជាតិដែលមិនអាចមានភាគីណាមួយធ្វើការបំពានបានឡើយ។[63] ចំណែកឯប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី ក៏បានបង្កើតច្បាប់មជ្ឈត្តការសម្របតាមស្ថានភាពមជ្ឈត្តការនៃប្រទេសរបស់ខ្លួនដើម្បីប្រើប្រាស់និងអនុវត្តក្នុងដែនដីរបស់ខ្លួនផងដែរ។

### ១.២.១. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា(*Commercial Arbitration Law of Cambodia*) បានអនុម័តដោយសភានៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៦ ក្នុងគោលបំណងដើម្បីសម្រួលដល់ការដោះស្រាយជាបន្ទាន់តាមរយៈការផ្សះផ្សារនូវវិវាទពាណិជ្ជកម្ម ដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទដើម្បីការពារសិទ្ធិ និងផលប្រយោជន៍នៃភាគីវិវាទ និងលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។[64] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក៏ត្រូវបានបង្កើតឡើងដោយយកលំនាំច្បាប់គម្រូមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ( *UNCITRAL Model Law*) ឆ្នាំ១៩៨៥ផងដែរ។

គួរបញ្ជាក់ផងដែរថា ពាក្យកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនិងពាក្យកិច្ចព្រមព្រៀងផ្សះផ្សាគឺមានអត្ថ-ន័យដូចគ្នានិងអាចប្រើប្រាស់ជំនួសគ្នាបាន។ កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម គឺសំដៅទៅលើកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬវិវាទបែបណាមួយដែលកើតឡើង ឬដែលអាចកើតឡើងកើត

---

[62] ជម្រើសទី២-មាត្រា៧នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ,១៩៨៥(វិសោធនកម្ម២០០៦)។។

[63] United Nations Commission on International Trade Law, *UNCITRAL Digest of Case Law on the Model Law on International Commercial Arbitration*, ឆ្នាំ២០១២, ទំព័រទី៩៧ និងកថាខណ្ឌទី៤ និងទំព័រទី១០០ និងកថាខណ្ឌទី៤ ។

[64] មាត្រា១ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

រវាងភាគីវិវាទនានាដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យាឬគ្មានក៏ដោយ ។[65] ចំណុចចម្បងនៃទម្រង់សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគឺ រួមបញ្ចូលទាំងខសន្យាមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា និងកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកដែលត្រូវតែធ្វើឡើងក្នុងទម្រង់សរសេរជាលាយលក្ខណ៍អក្សរ។[66] កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងទម្រង់សរសេរជាលាយលក្ខណ៍អក្សរត្រូវមានការចុះហត្ថលេខាដោយភាគីនៃកិច្ចព្រមព្រៀង ឬមានការផ្ញើរលិខិតស្នាម ឬមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិចដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នារបស់ភាគី ឬមានការផ្លាស់ប្តូរទៅវិញទៅមកនូវពាក្យទាមទារ ឬពាក្យដោះសារដែលក្នុងនោះភាគីវិវាទមួយបានទាមទារហើយមិនត្រូវបានបដិសេធដោយភាគីម្ខាងទៀតនៃវិវាទ។[67] រីឯសេចក្តីយោងក្នុងកិច្ចសន្យា និងឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការគឺអាចក្លាយជាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបាន លុះត្រាតែកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យាផងដែរ។[68] លើសពីនេះទៅទៀត ក្នុងបរិបទកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ពាក្យថាពាណិជ្ជកម្មបានកំណត់ឲ្យត្រូវបកស្រាយទូលំទូលាយដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យាឬគ្មានកិច្ចសន្យាក៏ដោយ ។[69] ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍គឺរាប់បញ្ចូលដូចជាៈ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗកិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។[70]

ម៉្យាងទៀត កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអាចនឹងកើតមាននូវអសុពលភាព ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានចែងនូវចំណុច ផ្ទុយនឹងបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ដោយសារតែសកម្មភាពនេះចាត់ទុកជាភាពមិនអាចបំពេញនូវលក្ខខណ្ឌសារជាតុនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម។ បទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំមួយចំនួនដែលមិន

[65] មាត្រា២(ឃ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។
[66] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។
[67] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។
[68] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។
[69] មាត្រា២(ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។
[70] មាត្រា២(ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

អាចបំពានបានគឺមានដូចជាៈ ភាគីត្រូវមានសេរីភាពទាក់ទងនឹងនីតិវិធីដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ [71] ភាគីនៃវិវាទត្រូវបានយកចិត្តទុកដាក់ស្មើគ្នានិងផ្តល់ឱកាសពេញលេញដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួននៅក្នុងដំណើរការនីតិវិធី[72]។

### ១.២.២. ច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ីឆ្នាំ២០០៥(Malaysia Arbitration Act 2005) ត្រូវបានចូលជាធរមានសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសម៉ាឡេស៊ី។ លើសពីនេះទៅទៀត ច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី បានបង្កើតឡើងលក្ខណៈជាកំណែទម្រង់ច្បាប់ទាក់ទងនឹងមជ្ឈត្តការក្នុងស្រុករបស់ម៉ាឡេស៊ី ព្រមទាំងមានការផ្តល់ជូនបន្ថែមនូវមជ្ឈត្តការអន្តរជាតិរួមទាំងការទទួលស្គាល់ និងការអនុវត្តន៍សេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសរួមទាំងបញ្ហាពាក់ព័ន្ធឲ្យកាន់តែប្រសើរ។ [73] ចំពោះប្រទេសម៉ាឡេស៊ីវិញក៏មិនខុសគ្នាពីប្រទេសឯទៀតផងដែរ គឺច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ីត្រូវបានអនុម័តដោយយកលំនាំតាមគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ(*UNCITRAL Model Law*) ឆ្នាំ១៩៨៥ក្នុងគោលបំណងដើម្បីសម្រេចបាននូវការលើកកម្ពស់និងការអនុវត្តស្របគ្នានៃរបបមជ្ឈត្តការនៅក្នុងសកលលោកទាំងមូល។[74]

នៅក្នុងច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី ពាក្យកិច្ចព្រមព្រៀងមជ្ឈត្តការគឺសំដៅទៅដល់កិច្ចព្រមព្រៀងរវាងភាគីក្នុងការបញ្ជូនទៅមជ្ឈត្តការទាក់ទងនឹងវិវាទរបស់ខ្លួនទាំងអស់ ឬវិវាទជាក់លាក់ណាមួយដែលបានកើតឡើង ឬដែលអាចនឹងកើតឡើងរវាងភាគីទាក់ទងនឹងទំនាក់ទំនងផ្លូវច្បាប់ដែលបានកំណត់ទោះបីតាមរយៈកិច្ចសន្យាក្តី ឬមិនតាមរយៈកិច្ចសន្យាក្តី។[75] កិច្ចព្រមព្រៀងមជ្ឈត្តការអាចធ្វើឡើងក្នុងទម្រង់ខសន្យាមជ្ឈត្តការនៅក្នុងកិច្ចព្រមព្រៀងក៏បានឬអាចធ្វើក្នុងទម្រង់កិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកក៏បាន។ [76] ចំពោះទម្រង់សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មរបស់ច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី២០០៥ គឺតម្រូវឲ្យសរសេរជាលាយលក្ខណ៍អក្សរ។ [77] កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនឹងចាត់ទុកថាធ្វើឡើងដោយការសរសេរជាលាយលក្ខណ៍អក្សរលុះត្រាតែវាជាឯកសារដែលមានចុះហត្ថលេខាភាគី[78]ឬមានការផ្លាស់ប្តូរអក្សរតាមរយៈទូរគមនាគមន៍ឬតាមរយៈ

---

[71] មាត្រា២៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

[72] មាត្រា២៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

[73] ច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥, ទំព័រទី៧។

[74] Rajoo, Sundra, Choong Yeow Choy. "The Arbitration Regime in Malaysia: A De Jure Model Law Jurisdiction?", *The UNCITRAL Model Law and Asian Arbitration Laws* (Cambridge University Press 2018) ទំព័រទី១៥១។

[75] ផ្នែកទី៩(១) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[76] ផ្នែកទី៩(២) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[77] ផ្នែកទី៩(៣) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[78] ផ្នែកទី៩(៤) (ក) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

មធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលផ្តល់នូវកំណត់ត្រានៃកិច្ចព្រមព្រៀង[79] ឬមានការផ្លាស់ប្តូរសេចក្តីថ្លែងការណ៍មួយនៃការទាមទារ និងការការពារជាហេតុធ្វើឲ្យមានការកកើតឡើងនូវកិច្ចព្រមព្រៀងដែលមានការចោទប្រកាន់ដោយភាគីម្ខាង និងមិនមានការបដិសេធពីភាគីម្ខាងទៀតផងដែរ[80]។ ចំពោះសេចក្តីយោង នៅក្នុងកិច្ចព្រមព្រៀងដែលមានចែងពីខសន្យាមជ្ឈត្តការវិញគឺអាចចាត់ទុកថាជាកិច្ចព្រមព្រៀងមជ្ឈត្តការ លុះត្រាតែវាស្ថិតនៅក្នុងទម្រង់កិច្ចព្រមព្រៀងដែលបានសរសេរជាលាយលក្ខណ៍អក្សរហើយ សេចក្តីយោងនេះគឺប្រៀបដូចជាខណៈមួយដែលជាផ្នែកនៃកិច្ចព្រមព្រៀងទាំងមូល។[81]

នៅក្នុងបរិបទច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ី កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមិនប្រឈមនឹងអសុពលភាពនៃលក្ខខណ្ឌសារធាតុនោះទេ ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមិនមានចែងអ្វីផ្ទុយនឹងបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំនៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី។ បទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំនៃច្បាប់មានដូចជា៖ កម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តការមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ (សណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេសម៉ាឡេស៊ី)[82] ភាគីនៃវិវាទត្រូវបានយកចិត្តទុកដាក់ស្មើគ្នានិងផ្តល់ឱកាសពេញលេញដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួននៅក្នុងដំណើរការនីតិវិធី[83] និងសេរីភាពរបស់ភាគីទាក់ទងនឹងនីតិវិធីដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ[84]។

### ១.៣. វិធានមជ្ឈត្តការពាណិជ្ជកម្ម

ទោះជាច្បាប់មជ្ឈត្តការពាណិជ្ជកម្មបានបង្កើតឡើងក៏ដោយ ភាគីនៃមជ្ឈត្តការនៅតែមានសេរីភាពក្នុងការយល់ព្រមលើនីតិវិធីសម្រាប់ដំណើរការមជ្ឈត្តការរបស់ពួកគេ ដែលអាចជានីតិវិធីលំនាំមានចែងក្រោមច្បាប់ស្រាប់ឬនីតិវិធីផ្សេងខុសពីនីតិវិធីលំនាំដែលមានចែងក្រោមច្បាប់ស្រាប់ក៏បាន។ ដោយសារតែស្ថាប័នមជ្ឈត្តការនីមួយៗមានវិធានមជ្ឈត្តការផ្ទាល់របស់ខ្លួនបន្ថែមទៀត សម្រាប់គ្រប់គ្រងនីតិវិធីនៃដំណើរការនៃមជ្ឈត្តការរបស់ខ្លួន ក៏ដូចជាសម្រួលដល់ភាគីក្នុងការជ្រើសរើសនូវនីតិវិធីណាមួយ ដែលខ្លួនពេញចិត្តនិងមានប្រសិទ្ធភាពក្នុងដោះស្រាយវិវាទរបស់ខ្លួន។ មជ្ឈត្តការពាណិជ្ជកម្មនៃស្ថាប័នមជ្ឈត្តការនីមួយៗតែងតែមានការបែងចែកនូវការដោះស្រាយវិវាទតាមពីរប្រភេទគឺ៖ ការដោះស្រាយតាមរយៈមជ្ឈត្តការស្ថាប័នដោយស្ថិតក្រោមការគ្រប់គ្រងនៃវិធានមជ្ឈត្តការរបស់ស្ថាប័ន (*Institutional Arbitration*) និងការដោះស្រាយតាមរយៈមជ្ឈត្តការពិសេស (*Ad hoc*

[79] ផ្នែកទី៩(៤)(ខ) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[80] ផ្នែកទី៩(៤)(គ) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[81] ផ្នែកទី៩(៥) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[82] ផ្នែកទី៤(១) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[83] ផ្នែកទី២០ នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

[84] ផ្នែកទី២១ នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី,៣០ ធ្នូ ២០០៥។

*Arbitration*) ដែលគូភាគីអាចព្រមព្រៀងជ្រើសរើសច្បាប់នីតិវិធីណាមួយសម្រាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តការរបស់ខ្លួនដោយសេរី។ ក៏ប៉ុន្តែការដោះស្រាយតាមរយៈមជ្ឈត្តការពិសេសគឺមិនសូវជាពេញនិយមនោះទេពីព្រោះតែទាមទារនូវចំណេះដឹងខ្ពស់រួមនឹងបទពិសោធន៍ច្រើនរបស់មជ្ឈត្តករ និងមេធាវីក្នុងដំណើរការដោះស្រាយទើបការដោះស្រាយវិវាទសម្រេចបាននូវលទ្ធផលល្អប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ១.៣.១. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (*NCAC*) ក៏ជាសមិទ្ធផលកកើតតាមរយៈច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជាដែលត្រូវបានអនុម័តនៅឆ្នាំ ២០០៦ ដោយមានភ្ជាប់ជាមួយនូវអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលបានអនុម័តកាលពីឆ្នាំ ២០០៩។[85] នៅឆ្នាំថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏បានអនុម័តនូវវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (*Arbitration Rules of the National Commercial Arbitration Centre*) និងបទបញ្ញត្តិផ្ទៃក្នុងសម្រាប់ការឆ្ពោះទៅរកប្រតិបត្តិការពេញលេញនៃការដោះស្រាយវិវាទពាណិជ្ជកម្មបន្ថែមទៀត។[86]

ដោយសារតែវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ផ្តោតសំខាន់តែទៅលើនីតិវិធីនៃដំណើរការមជ្ឈត្តការវិធានទូទៅ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងសិទ្ធិរបស់ភាគីដែលគ្រប់គ្រងដោយស្ថាប័ននៃមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ទើបធ្វើឲ្យចំណុចវិនិច្ឆ័យទាក់ទងនឹងអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការមានតិចតួច។ នៅក្នុងបរិបទនៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មវិញ គឺកើតមានឡើងប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានចែងបំពាននឹងការទទួលបាននូវការយកចិត្តទុកដាក់ស្មើៗគ្នា និងការផ្តល់ឱកាសសមរម្យដើម្បីបង្ហាញពីរឿងរ៉ាវរបស់ភាគីនីមួយៗក្នុងដំណើរការមជ្ឈត្តការ។[87]

### ១.៣.២. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី

មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី(*AIAC*) បានផ្លាស់ប្តូរជាផ្លូវការពីឈ្មោះមជ្ឈមណ្ឌលមជ្ឈត្តការតំបន់គូឡាឡាំពួរ(*KLRCA*)។[88] ច្បាប់មជ្ឈត្តការក៏ត្រូវបានធ្វើវិសោធនកម្មដោយរួមទាំងមានការពិនិត្យនិងអនុម័តនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ដើម្បីបញ្ជាក់ពីការផ្លាស់ប្តូរឈ្មោះមជ្ឈត្តការម៉ាឡេស៊ី។ ដោយសារតែការផ្លាស់ប្តូរ

---

[85] មាត្រា១៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស / រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

[86] មាត្រា១០ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស / រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

[87] វិធាន២០.១ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា, ១១ កក្កដា ២០១៤។

[88] Asian International Arbitration Centre, *About AIAC*, អាចរកបាននៅ https://www.aiac.world/About-AIAC- (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

ឈ្មោះគឺជាផ្នែកមួយនៃការផ្លាស់ប្តូរលក្ខណៈទ្រង់ទ្រាយធំសម្រាប់មជ្ឈមណ្ឌល ហើយក៏មានភ្ជាប់គោលបំណងពង្រឹងបន្ថែមទៀតនូវវត្តមាននៃមជ្ឈត្តការម៉ាឡេស៊ីទាំងនៅក្នុងតំបន់និងពិភពលោក។[89] បន្ទាប់ពីមានការផ្លាស់ប្តូរឈ្មោះមជ្ឈត្តការរួចរាល់ មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ីក៏បានបង្កើតនិងអនុម័តវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី(*Arbitration Rules of Asian International Arbitration Centre*) នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨ សម្រាប់គ្រប់គ្រងដំណើរការនៃមជ្ឈត្តការឲ្យកាន់តែល្អប្រសើរ។[90]

វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី គឺផ្តោតទៅលើតែវិធានទូទៅ នីតិវិធីនៃដំណើរការមជ្ឈត្តការ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងសិទ្ធិរបស់ភាគីដែលគ្រប់គ្រងដោយស្ថាប័ននៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី មូលហេតុនេះហើយទើបមូលដ្ឋាននៃការវិនិច្ឆ័យលើអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការគឺផ្តោតទៅលើច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ីវិញ។

សរុបជារួម ទោះបីជាភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជ្រើសរើសច្បាប់ឬវិធានមជ្ឈត្តការណាមួយដើម្បីគ្រប់គ្រងនីតិវិធីនៃដំណើរមជ្ឈត្តការក៏ដោយ តែត្រូវធានាថាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលបង្កើតឡើងនោះ មិនត្រូវបំពាននឹងលក្ខខណ្ឌទម្រង់និងលក្ខខណ្ឌសារធាតុរបស់ច្បាប់នៃអាសនៈមជ្ឈត្តការទេ។ ជាទូទៅបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំមានដូចជា៖ សេរីភាពរបស់ភាគីទាក់ទងនឹងនីតិវិធីដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ[91] ភាគីនៃវិវាទត្រូវបានយកចិត្តទុកដាក់ស្មើគ្នានិងផ្តល់ឱកាសពេញលេញដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួននៅក្នុងដំណើរការនីតិវិធី[92]។ល។

## ផ្នែកទី២ ច្បាប់ឬលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលអាចអនុវត្តបានក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម

នៅក្នុងសកលលោក អនុសញ្ញាស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ឬដែលហៅម្យ៉ាងទៀតបានថាអនុសញ្ញាទីក្រុងញូវយ៉ក(*New York Convention*) ត្រូវបានទទួលស្គាល់ជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិនៃមជ្ឈត្តការដែលមានសារៈសំខាន់ ពីព្រោះអនុសញ្ញាទីក្រុងញូវយ៉កធានាទៅលើការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស នៅដំណាក់កាលអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ

---

[89] Conventus Law, "Legal News & Analysis- Asia Pacific – Malaysia- Dispute Resolution", *KLRCA Officially Renamed The Asian International Arbitration Centre*, អាចរកបាននៅ http://www.conventuslaw.com/report/asian-international-arbitration-centre-aiac-to/ (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[90] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី, ៩ មីនា ២០១៨, ទំព័រទី៣។

[91] មាត្រា២៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស / រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; មាត្រា១៩ កថាខណ្ឌទី១ នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ, ១៩៨៥(វិសោធនកម្ម២០០៦)។

[92] មាត្រា២៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស / រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; មាត្រា១៨ នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ, ១៩៨៥(វិសោធនកម្ម២០០៦)។

ប្រទេសនៅក្នុងរដ្ឋដែលផ្តល់សច្ចាប័ន។ គួរបញ្ជាក់ផងដែរថាប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីក៏ជាភាគីហត្ថលេខីនៃអនុសញ្ញានេះផងដែរដោយកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦០ រីឯប្រទេសម៉ាឡេស៊ីវិញ បានចុះហត្ថលេខានៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៨៥។[93] លើសពីនេះទៅទៀត ក្នុងនាមជាប្រទេសភាគីហត្ថលេខីនៃអនុសញ្ញាទីក្រុងញូវយ៉ក ប្រទេសកម្ពុជាបានបង្កើតច្បាប់ស្តីពីការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស សម្រាប់អនុវត្តក្នុងយុត្តាធិការកម្ពុជាដោយភ្ជាប់នឹងការកំណត់អំពីនីតិវិធី និងសមត្ថកិច្ចនៃតុលាការព្រះរាជាណាចក្រកម្ពុជា នៅពេលមានការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តការបរទេសដោយផ្អែកលើអនុសញ្ញាទីក្រុងញូវយ៉ក។[94] ចំណែកប្រទេសម៉ាឡេស៊ីវិញ ច្បាប់នីតិវិធីដែលអនុវត្តសម្រាប់ការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តការបរទេសនៅក្នុងយុត្តាធិការប្រទេសម៉ាឡេស៊ី គឺមានចែងក្នុងច្បាប់មជ្ឈត្តការម៉ាឡេស៊ីផ្ទាល់តែម្តង។[95]

ដំណាក់ចុងក្រោយនៃដំណើរការនីតិវិធីមជ្ឈត្តការពាណិជ្ជកម្ម គឺទាក់ទងទៅនឹងការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករពីសំណាក់តុលាការដែលមានសមត្ថកិច្ច។ ជាទូទៅ តុលាការធ្វើការផ្ទៀងផ្ទាត់អំពីសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម មុននឹងធ្វើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តការបរទេស។ ការផ្ទៀងផ្ទាត់នេះអាចធ្វើឡើងដោយផ្អែកលើមូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តការបរទេសតាមរយៈការស្នើសុំរបស់ភាគីនៃវិវាទ ឬតាមរយៈការលើកឡើងដោយតុលាការឯកឯង ។ ដូចនេះហើយ ទើបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានសារៈសំខាន់ និងតម្រូវឲ្យមានបង្កើតឡើងដោយមិនផ្ទុយនឹងបញ្ញត្តិនៃអនុសញ្ញាស្តីពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ដោយសារតែវាមានឥទ្ធិពលទៅដល់ការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស។[96] ជាទូទៅ ភាគីត្រូវបង្ហាញឆន្ទៈក្នុងការយល់ព្រមបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងទម្រង់សរសេរស្របតាមលក្ខខណ្ឌតម្រូវរបស់អនុសញ្ញាស្តីពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស។[97] ទោះបីជាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មបង្កើតឡើងត្រឹមត្រូវស្រប

---

[93] New York Arbitration Convention, *Contracting State,* អាចរកបាននៅ http://www.newyorkconvention.org/countries (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[94] មាត្រា១ នៃច្បាប់ស្តីពីការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស, នស/ រកម/ ០៧០១/ ១០, ២៣ កក្កដា ២០០១។

[95] ជំពូកទី៨ នៃច្បាប់មជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[96] Born, Gary B. *International Commercial Arbitration*, 2nd edition, Kluwer Law International, ឆ្នាំ២០០៩ ទំព័រ៧១១។

[97] មាត្រា២ នៃអនុសញ្ញាស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស, ១៩៥៨។

តាមទម្រង់សរសេរពិតមែនក្តី ប៉ុន្តែកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនៅតែអាចក្លាយទៅជាអសុពលភាពប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មស្ថិតក្នុងចំណោមលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំងបីគឺ មោឃភាព ភាពមិនអាចប្រតិបត្តិបានឬអលទ្ធភាពក្នុងការអនុវត្ត និងភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋដែលនឹងត្រូវធ្វើការទទួលស្គាល់និងប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស។[98]

មោឃភាព គឺជាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលមានវិការៈឬអសុពលភាពដោយសារតែកាលៈទេសៈខាងក្រៅណាមួយ។[99] ចំពោះភាពមិនអាចប្រតិបត្តិបានឬអលទ្ធភាពក្នុងការអនុវត្ត គឺសំដៅដល់នីតិវិធីនានាដែលបានព្រមព្រៀងគ្នារវាងភាគី ប៉ុន្តែមិនអាចយកមកអនុវត្តបាន។[100] រីឯភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ គឺជាកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលចែងផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ។ យោងតាមការកម្រិតនូវស្តង់ដាឲ្យសមស្របជាមួយនឹងលិខិតនិងស្មារតីរបស់អនុសញ្ញាស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសសណ្តាប់ធ្នាប់សាធារណៈ វិធានច្បាប់ចាំបាច់គឺសំដៅលើមូលដ្ឋានគ្រឹះនៃសីលធម៌និងយុត្តិធម៌នៃរដ្ឋដែលត្រូវអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេសផ្ទាល់តែម្តង។[101]

សរុបមក កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មមានសុពលភាពជាប្រក្រតីដរាបណាកិច្ចព្រមព្រៀងមជ្ឈត្តកម្មពាណិជ្ជកម្មមិនស្ថិតក្នុងលក្ខខណ្ឌមោឃភាព ភាពមិនអាចប្រតិបត្តិបានឬអលទ្ធភាពក្នុងការអនុវត្តនិងភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ។ ប្រសិនបើសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបដិសេធក្នុងការទទួលស្គាល់និងការប្រតិបត្តិនៅក្នុងអាសនៈនៃមជ្ឈត្តការណាមួយ ដោយសារតែអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ ហេតុដូចនេះហើយទើបសេចក្តីសម្រេចមជ្ឈត្តករបរទេសនឹងមិនមានសុពលភាពនៅគ្រប់យុត្តាធិការទាំងអស់ដែលស្ថិតនៅក្រោមអនុភាពរបស់អនុសញ្ញាញូវយ៉ក ហើយទោះបីជាភាគីព្យាយាមស្វែងរកការអនុវត្តនៅឯយុត្តាធិការផ្សេងទៀតក៏ច្បាប់ហាមឃាត់មិនឲ្យមានការទទួលស្គាល់ និងប្រតិបត្តិបាននោះឡើយនៅគ្រប់ដែនសមត្ថកិច្ចទាំងអស់។ ដូចនេះ សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មពិតជាមានសារៈសំខាន់

[98] មាត្រា២(៣) និងមាត្រា៥(២) នៃអនុសញ្ញាស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស, ១៩៥៨; មាត្រា៨(១) នៃគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ១៩៨៥(វិសោធនកម្ម២០០៦); មាត្រា១៥(ក)(១) និងមាត្រា១៥(ខ)(២) នៃច្បាប់ស្តីពីការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស, នស/ រកម/ ០៧០១/ ១០, ២៣ កក្កដា ២០០១; ផ្នែកទី៣៩(១)(ក)(i), ផ្នែកទី៣៩(១)(ក)(ii) និង ផ្នែកទី៣៩(១)(ខ)(ii) នៃច្បាប់មជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥; Mistelis Loukas A. *CISG and Arbitration* រោងពុម្ពCambridge University Press, ឆ្នាំ២០១៤, ទំព័រ៣៩៣, និងBerg, Albert Jan van den. *The New York Arbitration Convention of 1958,* Kluwer Law International ឆ្នាំ១៩៨១, ទំព័រ១៥៤-១៦១។

[99] Born, Gary B. *International Commercial Arbitration*, 2nd edition, Kluwer Law International, ឆ្នាំ២០០៩, ទំព័រ៧១១។

[100] UNCITRAL Secretariat of United Nations Commission on International Trade Law, *Guide on the Convention on the Recognition and Enforcement of Foreign Arbitral Awards*, 2016 edition, ឆ្នាំ១៩៥៨, ទំព័រ៧២, កថាខណ្ឌទី១០៨។

[101] Fouchard, Philippe, Gailard Emmanuel, Goldman Berthold. *International Commercial Arbitration*, London: Kluwer Law International ឆ្នាំ១៩៩៦, ទំព័រ៩៩៦។

ណាស់ទាំងក្នុងដំណើរការនីតិវិធីមជ្ឈត្តការដើម្បីចាប់ផ្តើមដោះស្រាយជម្លោះពាណិជ្ជកម្ម ក៏ដូចជាក្នុងដំណាក់កាលទទួលស្គាល់និងប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសនៅក្នុងរដ្ឋដែលអាចធ្វើបាន ពីព្រោះវាគឺជាប្រយោជន៍របស់ភាគីនៃត្រូវផ្តោតសំខាន់និងគួរតែការពារស្របតាមគោលការណ៍គ្រឹះនៃមជ្ឈត្តការ៕

# ជំពូកទី២

# ប្រៀបធៀបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការ
# ពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងបញ្ហាប្រឈម

## ជំពូកទី២ ប្រៀបធៀបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងបញ្ហាប្រឈម

នាពេលបច្ចុប្បន្ន ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការនៅប្រទេសកំពុងអភិវឌ្ឍន៍គឺមានភាពរីកចម្រើន និងទទួលបាននូវការចាប់អារម្មណ៍ជាលំដាប់ពីសំណាក់អ្នកដែលអាចមានផលប្រយោជន៍ពាក់ព័ន្ធ ជាពិសេសគឺអ្នកជំនួញដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មទាំងលក្ខណៈជាតិនិងលក្ខណៈអន្តរជាតិ។ មូលហេតុនេះហើយទើបបានជា ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនចាប់ផ្តើមបង្កើតនូវមជ្ឈត្តការពាណិជ្ជកម្មនៅក្នុងយុត្តាធិការរបស់ខ្លួនឡើង។ នាពេលប៉ុន្មានឆ្នាំចុងក្រោយយើងសង្កេតឃើញមានមជ្ឈត្តការផ្នែកពាណិជ្ជកម្មថ្មីៗដែលទើបលេចរូបរាងឡើងបន្តបន្ទាប់ដូចជា៖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម(*NCAC*)[102] មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី(*AIAC*)[103] មជ្ឈមណ្ឌលប៊ីមបែសម្រាប់មជ្ឈត្តការអន្តរជាតិ(*MCIA*)[104] មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សានិងមជ្ឈត្តការកាតា(*QICCA*)[105]។

ក្នុងបរិបទនៃការទើបនឹងកកើតមានមជ្ឈត្តការក្នុងសភាពក្មេងខ្ចី ដំណើរការប្រព្រឹត្តទៅរបស់មជ្ឈត្តការនៅមិនទាន់រលូនទាំងស្រុងនោះទេ ដោយសារតែភាពក្មេងខ្ចីនៅក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មរួមផ្សំនឹងការខ្វះខាតនូវបច្ចេកទេសបទថៃមទាំងបទពិសោធន៍មួយចំនួន ទើបតម្រូវឲ្យមានការសិក្សាស្វែងយល់បន្ថែមទាក់ទងនឹងវិស័យមជ្ឈត្តការពាណិជ្ជកម្មតាមរយៈការបណ្តុះបណ្តាលពីអ្នកបច្ចេកទេសពាក់ព័ន្ធក្នុងមជ្ឈត្តការនៅប្រទេសអភិវឌ្ឍន៍ជាច្រើនដូចជា៖ មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី(*SIAC*)[106] មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិ

---

[102] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ១២៤ អនក្រ.បក, ១២ សីហា ២០០៩ ;National Commercial Arbitration Centre អាចរកបាននៅ http://www.ncac.org.kh/?fbclid=IwAR2mmTS9vC8Qu-l6HcSccfVmW2gTP_dnmEjdpYjl6rVuNnc_3svhKE4Bzjw (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[103] Asian International Arbitration Centre, *Arbitration*, រកបាននៅ https://www.aiac.world/Arbitration-Arbitration (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[104] Sanchez, Wilder Alejandro &Scripcari Lucia. "The New Arbitration Centers…", *Battle of the Seats: Developing Nations and International Arbitration Centers* អាចរកបាននៅ https://www.geopoliticalmonitor.com/battle-of-the-seats-developing-nations-and-international-arbitration-centers/ (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[105] Sanchez, Wilder Alejandro &Scripcari Lucia. "The New Arbitration Centers…", *Battle of the Seats: Developing Nations and International Arbitration Centers* អាចរកបាននៅ https://www.geopoliticalmonitor.com/battle-of-the-seats-developing-nations-and-international-arbitration-centers/ (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[106] Singapore International Arbitration Centre, *Arbitration*, អាចរកបាននៅ https://www.siac.org.sg/2014-11-03-13-33-43/why-siac/arbitration-in-singapore (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

ហុងកុង(*HKIAC*)[107] តុលាការក្រុងឡុងដ៍នៃមជ្ឈត្តការអន្តរជាតិ(*LCIA*)[108] និងសភាពាណិជ្ជកម្មអន្តរជាតិ (*ICC*)[109] ។ល។

ជាទូទៅ មជ្ឈត្តការផ្នែកពាណិជ្ជកម្មតែងតែមានចំណោទបញ្ហាគតិយុត្តទាក់ទងនឹងសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជារឿយៗ ប៉ុន្តែបញ្ហានេះច្រើនកើតមានចំពោះមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលទើបតែបង្កើតបានក្នុងរយៈពេលខ្លី ដោយសារតែកង្វះនូវការយល់ដឹងនិងការបណ្តុះបណ្តាលបន្ថែមទាក់ទងនឹងចំណុចនេះទៅកាន់បុគ្គលពាក់ព័ន្ធដូចជា៖ មជ្ឈត្តករ គូភាគីនៃវិវាទ(អ្នកជំនួញផ្នែកពាណិជ្ជកម្ម) ជាពិសេសគឺមេធាវីតែម្តង។

ម៉្យាងវិញទៀត បញ្ហាគតិយុត្តនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគឺមានមូលដ្ឋានគ្រឹះសម្រាប់ការតវ៉ាចំពោះការព្រមព្រៀងឬអត្ថិភាពរបស់កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ដែលមានលក្ខណៈស្រដៀងនឹងច្បាប់កិច្ចសន្យាផងដែរ។ មូលដ្ឋានទាំងនោះមានដូចជា៖ កង្វះកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មលើលក្ខខណ្ឌចាំបាច់ដែលអាចជាលក្ខខណ្ឌទម្រង់ឬលក្ខខណ្ឌសារធាតុ ការព្រមព្រៀងទៅលើមជ្ឈត្តការឬវិធានមជ្ឈត្តការដែលមិនទាន់កើតមាន ការព្រមព្រៀងផ្សេងៗដែលផ្ទុយនឹងវិធានផ្ទៃក្នុងរបស់មជ្ឈត្តការ ការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដោយស្ថិតក្នុងស្ថានភាពគំរាមកំហែងជាដើម។

បញ្ហាគតិយុត្តទាំងនេះផ្តល់ផលវិបាកចំពោះគូភាគីនៃកិច្ចព្រមព្រៀងយ៉ាងច្រើនដូចជា៖ អសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការផ្នែកវិវាទពាណិជ្ជកម្ម សេចក្តីសម្រេចមជ្ឈត្តកររអន្តរជាតិមិនទទួលស្គាល់ឬមិនអាចប្រតិបត្តិបាន ជាហេតុធ្វើឲ្យគូភាគីខាតបង់ផលប្រយោជន៍ទាំងពេលវេលានិងទឹកប្រាក់ចំណែកវិវាទនៅតែមិនទាន់ អាចដោះស្រាយបានដដែល។

## ផ្នែកទី១ ប្រៀបធៀបសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី

នៅពេលបញ្ហាគតិយុត្តិទាក់ទងនឹងសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការកើតឡើង មូលដ្ឋានក្នុងការវិនិច្ឆ័យគឺត្រូវធ្វើឡើងតាមរយៈច្បាប់ដែលគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនោះ។ ក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍វិញទោះបីជាមានប្រព័ន្ធមជ្ឈត្តការដោះស្រាយវិវាទពាណិជ្ជកម្មដូចគ្នាមែន ប៉ុន្តែប្រព័ន្ធច្បាប់គ្រប់

---

[107] Hong Kong International Arbitration Centre, *Arbitration*, អាចរកបាននៅ https://www.hkiac.org/arbitration/what-is-arbitration (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[108] London Court of International Arbitration, *Arbitration*, អាចរកបាននៅ https://www.lcia.org/LCIA/introduction.aspx (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

[109] International Chamber of Commerce, *Arbitration*, អាចរកបាននៅ https://iccwbo.org/dispute-resolution-services/arbitration/ (ចូលទស្សនាថ្ងៃទី២៨ ឧសភា ២០២០)។

គ្រងគឺមិនដូចគ្នាទាំងស្រុងនោះឡើយ ដែលវាអាចជះឥទ្ធិពលមកពីកត្តាស្មារតីនៃច្បាប់ក៏ដូចជាទំនោរនិងទម្លាប់នៃការអនុវត្តនៅក្នុងតំបន់ផងដែរ។ ចំពោះករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី ច្បាប់សម្រាប់អនុវត្តគ្រប់គ្រងទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម និងដំណើរការនីតិវិធីគឺមិនមានលក្ខណៈដូចគ្នាទាំងស្រុងទេ ពោលគឺមានចំណុចដូចគ្នាខ្លះនិងចំណុចខុសគ្នាខ្លះដែលនឹងត្រូវធ្វើការសិក្សាប្រៀបធៀបគ្នា។

**១.១. លក្ខណៈដូច**

លក្ខណៈដូចនៃកិច្ចសន្យាជាតិ ច្បាប់មជ្ឈត្តការ និងវិធានមជ្ឈត្តការរបស់ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីនឹងត្រូវបកស្រាយនិងរៀបរាប់ដូចខាងក្រោម៖

**១.១.១. ច្បាប់កិច្ចសន្យាជាតិ**

នៅក្នុងច្បាប់ស្តីពីកិច្ចសន្យារបស់ម៉ាឡេស៊ីបានចែងយ៉ាងច្បាស់ថាកិច្ចសន្យានិងកិច្ចព្រមព្រៀង គឺមានលក្ខណៈដូចគ្នា។ ទោះបីជា ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧មិនបានប្បញ្ញត្តិអំពីកិច្ចសន្យានិងកិច្ចព្រមព្រៀងដូចគ្នាក្តី ប៉ុន្តែពាក្យទាំងពីរនេះគឺមានអត្ថន័យដូចគ្នាហើយជាទូទៅត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកក្នុងការអនុវត្តផងដែរ។ ជាក់ស្តែងដូចមានចែងនៅក្នុងភាពចាំបាច់នៃទម្រង់កិច្ចសន្យា [110] ក៏ដូចជានិយមន័យនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ [111] និងការបង្កើតកិច្ចសន្យាលក់ទំនិញ [112] ជាដើម សុទ្ធតែមានលក្ខណៈរួមដែលអាចបញ្ជាក់អំពីន័យដូចគ្នារវាងកិច្ចសន្យានិងកិច្ចព្រមព្រៀងក្នុងបរិបទច្បាប់កម្ពុជា នៅត្រង់ចំណុចដែលប្បញ្ញត្តិអំពីកិច្ចសន្យាត្រូវបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគី។

ប្រសិនបើក្រឡេកមើលទៅលើធាតុផ្សំនៃកិច្ចសន្យាជាតិនៃប្រទេសនីមួយៗវិញ ច្បាប់របស់ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគឺមានចំណុចមួយចំនួនដូចគ្នាឬប្រហាក់ប្រហែលគ្នាត្រង់ចំណុចដូចជា៖ សមត្ថភាពភាគីក្នុងការបង្កើតកិច្ចសន្យា(កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម)និងសមត្ថភាពខាងឆន្ទៈរបស់ភាគីនៃកិច្ចសន្យា។

សមត្ថភាពភាគីក្នុងការបង្កើតកិច្ចសន្យា(កិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម) គឺសំដៅទៅលើសមត្ថភាពរបស់ភាគីក្នុងការធ្វើសកម្មភាពទាក់ទងនឹងកិច្ចសន្យា ដោយមិនមែនជាបុគ្គលដែលត្រូវបានកម្រិតនូវសមត្ថ ភាពក្នុងការធ្វើសកម្មភាពដែលច្បាប់បានកំណត់[113] ហើយជាពិសេសតម្រូវឲ្យជានីតិជនថែមទៀតពោលគឺមាន អាយុ ១៨ឆ្នាំឡើងទៅ។ [114] រីឯការបង្ហាញឆន្ទៈរបស់ភាគីនៃកិច្ចសន្យា គឺត្រូវធ្វើឡើងដោយសេរីនិងពិតប្រាកដដោយ

---

[110] មាត្រា៦៣៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[111] មាត្រា៥៧៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[112] មាត្រា៥១៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[113] មាត្រា១៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១២ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[114] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១១ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០និងផ្នែកទី២ នៃច្បាប់ស្តីពីនីតិភាព(*Malaysia Age of Majority Act*), ២២ មេសា ១៩៧១។

គ្មានស្ថិតនៅក្នុង ការភ័ន្តច្រឡំឬហៅថាកំហុសនៃអង្គហេតុ[115] ការឆបោក[116] ការទទួលបានពត៌មានមិនពិតជាហេតុធ្វើឲ្យមានការ បង្ហាញខុស[117] ការរំលោភលើស្ថានភាពឬការស្ថិតនៅក្រោមឥទ្ធិពល[118] ការគម្រាមកំហែង ឬស្ថានភាពនៃការ បង្ខិតបង្ខំ[119] នោះទេ។

### ១.១.២. ច្បាប់មជ្ឈត្តការ

ជាទូទៅ ប្រទេសនីមួយៗមានច្បាប់មជ្ឈត្តការរបស់ខ្លួនសម្រាប់គ្រប់គ្រងនិងអនុវត្តចំពោះប្រព័ន្ធមជ្ឈត្ត ការរបស់ខ្លួន។ ចំពោះប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគឺបានបង្កើតច្បាប់មជ្ឈត្តការរបស់ខ្លួនដោយយកលំនាំតាមគម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ( *UNCITRAL Model Law*) ឆ្នាំ១៩៨៥ដូចគ្នាដែលជាហេតុធ្វើឲ្យច្បាប់មជ្ឈត្តការរបស់ប្រទេសទាំងពីរនេះមានចំណុចដូចគ្នាច្រើនទាក់ទងនឹងនិយមន័យ ធាតុផ្សំ និងលក្ខខណ្ឌនៃការវិនិច្ឆ័យផ្សេងៗទៀតដូចជា៖ និយមន័យនៃកិច្ចព្រមព្រៀងមជ្ឈត្តការ[120] ប្រភេទនៃកិច្ចព្រមព្រៀងមជ្ឈត្តការ[121] ទម្រង់នៃកិច្ចព្រមព្រៀងមជ្ឈត្តការ[122] លក្ខខណ្ឌនៃទម្រង់កិច្ចព្រមព្រៀងមជ្ឈត្តការ[123] លក្ខខណ្ឌនៃការវិនិច្ឆ័យលើសេចក្តីយោងក្នុងកិច្ចសន្យាដែលចាត់ទុកជាកិច្ចព្រមព្រៀងមជ្ឈត្តការ[124] លក្ខខណ្ឌសារជាតុទាក់ទងនឹងប្បញ្ញត្តិមានអានុភាពចាប់បង្ខំដែលមិនអាចបំពានបាន ដោយសារតែមានផលវិបាកធ្វើឲ្យមានអសុពលភាពនៃកិច្ចព្រម

[115] មាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី២១ និងផ្នែកទី២៣ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី, ១៩៥០។

[116] មាត្រា៣៤៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១៧ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[117] មាត្រា៣៤៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១៨ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[118] មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១៦ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[119] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧; ផ្នែកទី១៥ នៃច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[120] មាត្រា២(ឃ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; ផ្នែកទី៩(១) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[121] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; ផ្នែកទី៩(២) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[122] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; ផ្នែកទី៩(៣) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[123] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; ផ្នែកទី៩(៤) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[124] មាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦; ផ្នែកទី៩(៥) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

ព្រៀងមជ្ឈត្តការ(សេរីភាពរបស់ភាគីក្នុងការជ្រើសរើសនីតិវិធីដែលមជ្ឈត្តកម្មត្រូវអនុវត្ត [125] ការយកចិត្តទុកដាក់ស្មើគ្នានិងការផ្តល់ឱកាសពេញ លេញដល់ភាគីនៃវិវាទក្នុងដំណើរការនីតិវិធី[126])។

**១.១.៣. វិធានមជ្ឈត្តការ**

យោងលើហេតុផល ដែលវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ប្រទេសកម្ពុជា) និងវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី(ប្រទេសម៉ាឡេស៊ី) គឺជាវិធានដែលបង្កើតឡើងសម្រាប់ផ្តោតសំខាន់តែទៅលើនីតិវិធីនៃដំណើរការមជ្ឈត្តការវិធានទូទៅ និងបទប្បញ្ញត្តិផ្សេងៗ ទាក់ទងនឹងសិទ្ធិរបស់ភាគីដែលគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តការនៃប្រទេសរៀងៗខ្លួនដូចគ្នា។

**១.២. លក្ខណៈខុស**

ចំពោះចំណុចដែលមានលក្ខណៈខុសគ្នារវាងនៃកិច្ចសន្យាជាតិ ច្បាប់មជ្ឈត្តការ និងវិធានមជ្ឈត្តការរបស់ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគឺមានការប្រៀបធៀបគ្នាដូចខាងក្រោម៖

**១.២.១. ច្បាប់កិច្ចសន្យា**

ទាក់ទងនឹងចំណុចនៃការបង្ហាញឆន្ទៈរបស់ភាគីក្នុងការបង្កើតកិច្ចសន្យាឬកិច្ចព្រមព្រៀង ក្រមរដ្ឋប្បវេណីកម្ពុជាគឺមានចែងពីស្ថានភាពច្បាស់លាស់និងច្រើនជាងច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ី។ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាបានចែងអំពីវិការៈនៃបង្ហាញឆន្ទៈរបស់ភាគីនៃកិច្ចសន្យាឬកិច្ចព្រមព្រៀង ដែលជាហេតុធ្វើឲ្យកើតមានអសុពលភាព ប្រសិនបើការបង្ហាញឆន្ទៈរបស់ភាគីធ្វើឡើងក្នុងស្ថានភាពកេងចំណេញហួសហេតុ[127] ឋបនីយផ្លូវចិត្ត[128] និងឆន្ទៈមិនពិត[129]។

រីឯចំណុចអាចធ្វើឲ្យមានអសុពលភាពកិច្ចសន្យាឬកិច្ចព្រមព្រៀង ដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចសន្យាម៉ាឡេស៊ីឆ្នាំ១៩៥០ហើយក្នុងក្រមរដ្ឋប្បវេណីមិនបានចែងវិញមានដូចជា៖ កិច្ចសន្យាឬកិច្ចព្រមព្រៀងដែលមានចែងភ្ជាប់ជាមួយនឹងកំហុសនៃអង្គហេតុ[130] និងកិច្ចសន្យាឬកិច្ចព្រមព្រៀងដែលមានចែងអំពីផលនៃតម្លៃតបស្នងមិនស្របច្បាប់[131]។

[125] មាត្រា២៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦; ផ្នែកទី២១(១) នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[126] មាត្រា២៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦; ផ្នែកទី២០ នៃច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

[127] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[128] មាត្រា៣៥២ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[129] មាត្រា៣៥៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា, នស / រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

[130] ផ្នែកទី២២ នៃច្បាប់កិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[131] ផ្នែកទី២៤ នៃច្បាប់កិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

### ១.២.២. ច្បាប់មជ្ឈត្តការ

ដោយសារតែច្បាប់មជ្ឈត្តការនៃប្រទេសទាំងពីរមានចំណុចដូចគ្នាច្រើន ដូចនេះហើយទើបចំណុចដែលជាកត្តាវិនិច្ឆ័យលើទម្រង់សុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម មានលក្ខណៈខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ ជាក់ស្តែងនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មរបស់កម្ពុជាមានចែងបញ្ជាក់អំពីនិយមន័យនិងវិធាននៃការបកស្រាយទៅលើពាក្យពាណិជ្ជកម្មច្បាស់និងទូលំទូលាយ [132] ស្របពេលដែលច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ីមិនបានចែង។ ម្យ៉ាងទៀត ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មរបស់កម្ពុជាគឺផ្តោតទាក់ទងនឹងពាណិជ្ជកម្មប៉ុណ្ណោះ រីឯច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ីវិញមិនផ្តោតលើមជ្ឈត្តការពាណិជ្ជកម្មតែមួយមុខទេ។ ផ្ទុយមកវិញ លក្ខណៈខុសគ្នារវាងច្បាប់ស្តីពីមជ្ឈត្តការរបស់ម៉ាឡេស៊ីមានចែងអំពីចំណុចកម្មវត្ថុនៃមជ្ឈត្តការមានលក្ខណៈផ្សេងពីច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មរបស់កម្ពុជាមួយចំនួនដូចជា៖ កម្មវត្ថុនៃមជ្ឈត្តការគឺសំដៅលើវិវាទណាមួយ ដែលភាគីទាំងសងខាងបានយល់ព្រមដាក់បញ្ជូនទៅមជ្ឈត្តការតាមរយៈកិច្ចព្រមព្រៀងមជ្ឈត្តការ ដែលអាចត្រូវកំណត់ដោយមជ្ឈត្តការ លើកលែងតែកិច្ចព្រមព្រៀងមជ្ឈត្តការផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ [133] ឬជាអង្គហេតុដែលច្បាប់សរសេរបានផ្តល់យុត្តាធិការទាក់ទងនឹងបញ្ហាណាមួយនៅឯតុលាការ ប៉ុន្តែមិនសំដៅទៅលើការវិនិច្ឆ័យបញ្ហាដោយមជ្ឈត្តការ រួមទាំងមិនបង្ហាញអំពីវិវាទនៃបញ្ហាដែលមិនមានសមត្ថភាពវិនិច្ឆ័យដោយមជ្ឈត្តការទៀតផង [134]។

### ១.២.៣. វិធានមជ្ឈត្តការ

ទាក់ទងនឹងលក្ខណៈខុសគ្នាត្រង់ចំណុចវិនិច្ឆ័យលើសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការវិញ នៅក្នុងវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ីរបស់ប្រទេសម៉ាឡេស៊ី មានលក្ខណៈខុសគ្នាត្រង់វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា មានប្បញ្ញត្តិច្បាស់អំពីការទទួលបាននូវការយកចិត្តទុកដាក់ស្មើៗគ្នា និងការផ្តល់ឱកាសសមរម្យដើម្បីបង្ហាញពីរឿងរ៉ាវរបស់ភាគីនីមួយៗក្នុងដំណើរមជ្ឈត្តការ ដែលជាបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំ និងមិនអាចបំពានបាន ។

---

[132] មាត្រា២(ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម, នស / រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦ ។

[133] ផ្នែកទី៤(១) នៃច្បាប់កិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

[134] ផ្នែកទី៤(២) នៃច្បាប់កិច្ចសន្យាម៉ាឡេស៊ី,១៩៥០។

## ផ្នែកទី២ បញ្ហាប្រឈមនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី

ទោះបីជាប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្មត្រូវបានទទួលស្គាល់ជាសកលកាន់តែទូលំទូលាយក៏ដោយ ប៉ុន្តែនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ នៅតែកើតមានបញ្ហាទាក់ទងនឹងទម្រង់សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជារឿយៗដោយឧបសគ្គទាំងនោះភាគច្រើនកើតឡើងទាក់ទងនឹងច្បាប់ជាតិតែម្តង។ ពីព្រោះច្បាប់ជាតិទាំងអស់មិនមានលក្ខណៈដូចឬស្របនឹងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិទាំងអស់នោះទេ។ បញ្ហាទាំងនោះរាប់បញ្ចូលដូចជា៖ លក្ខខណ្ឌទម្រង់ លក្ខខណ្ឌសារធាតុ ដែនកំណត់នៃអានុភាព កម្មវត្ថុ យុត្តាធិការ។ល។ ដោយយោងលើកត្តាច្បាប់ជាតិនៃប្រទេសនីមួយៗមិនមានលក្ខណៈដូចគ្នាទាំងស្រុង ទើបធ្វើឲ្យករណីដែលប្រទេសនីមួយៗជួបប្រទះ និងដោះស្រាយទាក់ទងនឹងបញ្ហាសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការមិនដូចគ្នាទាំងស្រុងទេ។

### ១.១. ករណីកម្ពុជា

ចាប់តាំងពីមានការបង្កើតមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាជាផ្លូវការរហូតមកដល់ដើមឆ្នាំ២០១៩ មជ្ឈត្តការពាណិជ្ជកម្មទើបតែទទួលបានសំណុំរឿងចំនួន១៤ប៉ុណ្ណោះ ដែលបានបញ្ជូនមកនិងគ្រប់គ្រងដោយរដ្ឋបាលនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ [135] ដោយសារតែចំនួនសំណុំរឿងនៅមានតិចនៅឡើយទើបបានជាតុលាការកម្ពុជា មិនទាន់បានទទួលសំណុំរឿងប្តឹងផ្ទាល់ពីសំណាក់ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មទាក់ទងនឹងបញ្ហាសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនៅឡើយទេ។ ប៉ុន្តែទាក់ទងនឹងបញ្ហាអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម គឺនៅតែមានការលើកឡើងជារឿយៗនៅក្នុងដំណើរការមជ្ឈត្តការវិញដោយសាលាក្តីមជ្ឈត្តការនឹងធ្វើការពិចារណា និងកាត់សេចក្តីដោយមជ្ឈត្តករផ្ទាល់តែម្តង។

### ១.២. ករណីម៉ាឡេស៊ី

គិតត្រឹមឆ្នាំ២០២០សំណុំរឿងមជ្ឈត្តការលើសពី៧០០ករណី បានដាក់ស្នើមកមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ីដើម្បីធ្វើការដោះស្រាយជម្លោះតាមប្រព័ន្ធមជ្ឈត្តការរបស់ប្រទេសម៉ាឡេស៊ី។ នាពេលប៉ុន្មានឆ្នាំចុងក្រោយមជ្ឈត្តការរបស់ម៉ាឡេស៊ីមានការរីកចម្រើននិងជាទីពេញនិយមគួរឲ្យកត់សម្គាល់។ ក៏ប៉ុន្តែ ដោយសារសន្ទុះនៃការដោះស្រាយវិវាទពាណិជ្ជកម្មមានការកើនឡើងភ្លាមៗ បញ្ហាទាក់ទងនឹងនឹងអសុពលភាពនៃកិច្ចព្រម

---

[135] EUROCHAM-CAMBODIA, "EUROCHAM elected to the NCAC Board", *News*, អាចរកបាននៅ https://www.eurocham-cambodia.org/post/604/EuroCham-elected-to-the-NCAC-Board#:~:text=Since%20its%20official%20launch%2C%2060,dispute%20exceeding%20%2436%20million%20USD. (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០២០)។

ព្រៀងមជ្ឈត្តការពាណិជ្ជកម្មក៏កើតមានឡើងទន្ទឹមគ្នាច្រើនផងដែរ។ ជាក់ស្ដែង នៅក្នុងប្រទេសម៉ាឡេស៊ីគឺមានករណីខ្លះធ្វើការតវ៉ានិងដោះស្រាយនៅក្នុងសវនការមជ្ឈត្តការផ្ទាល់ ហើយខ្លះទៀតវិញគឺភាគីនៃវិវាទធ្វើការប្ដឹងទៅតុលាការម៉ាឡេស៊ីដោយផ្ទាល់ពីសំណាក់ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មជារឿយៗ។ នៅក្នុងសំណុំរឿងនីមួយៗ គឺមានភ្ជាប់ជាមួយនឹងមូលដ្ឋានច្បាប់ដែលភាគីនៃវិវាទសំអាងទាក់ទងនឹងបញ្ហាសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មរបស់ខ្លួនផងដែរ។ ជាក់ស្ដែងក្នុងសំណុំរឿង Food Ingredients LCC v. Pacific Inter-Link Sdn Bhd[136] មានចំណុចវិវាទទាក់ទងនឹងអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការហើយករណីនេះត្រូវបានពិនិត្យនឹងពិភាក្សាអស់រយៈពេលជាយូរដោយតុលាការជាន់ខ្ពស់។ យោងតាមអង្គហេតុនៃសំណុំរឿងFood Ingredients LCC v. Pacific Inter-Link Sdn Bhd[137]តុលាការជាន់ខ្ពស់បានសន្និដ្ឋានថាកិច្ចព្រមព្រៀងមជ្ឈត្តការមិនមានសុពលភាពទេ ជាហេតុធ្វើឲ្យសវនការមិនអាចធ្វើការផ្ដល់ឬអនុវត្តសេចក្ដីសម្រេចរបស់មជ្ឈត្តករបាន។[138] ការសម្រេចបែបនេះគឺយោងលើមូលហេតុកិច្ចព្រមព្រៀងមជ្ឈត្តការមិនមានសុពលភាពនៅក្រោមច្បាប់ដែលភាគីជាប្រធាននៃអានុភាព ឬការដែលស្ថិតនៅក្នុងការចង្អុលបង្ហាញណាមួយនៅក្នុងច្បាប់របស់រដ្ឋដែលជាកន្លែងបង្កើតសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសតែម្ដង។[139]

សរុបជារួមមក មូលដ្ឋានលិខិតគតិយុត្តរបស់ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគឺមានលក្ខណៈវិនិច្ឆ័យដូចគ្នាច្រើនស្របពេលដែលលក្ខណៈខុសគ្នាគឺមានតិចតួចតែប៉ុណ្ណោះ។ ក្នុងបរិបទដែលប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីជាប្រទេសកំពុងអភិវឌ្ឍន៍ បញ្ហាទាក់ទងនឹងទម្រង់សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនឹងកើតមានឡើងដោយជៀសពុំរួច ដោយសារកត្តាយល់ដឹងរបស់បុគ្គលពាក់ព័ន្ធនៅមានកម្រិតរួមទាំងការអប់រំផ្សព្វផ្សាយមិនទាន់បានគ្រប់គ្រាន់ចំពោះគ្រប់មជ្ឈដ្ឋាននៅក្នុងប្រទេសនីមួយៗរបស់ខ្លួន។ ប្រសិនជាធ្វើការប្រៀបធៀបរវាងបញ្ហាទម្រង់សុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការ ដែលកើតឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាំងពីរវិញ គឺសង្កេតឃើញថាប្រទេសម៉ាឡេស៊ីមានការជួបប្រទះច្រើនជាងដោយសារតែមជ្ឈត្តការនៅប្រទេសម៉ាឡេស៊ីបានបង្កើតយ៉ូរជាង និងទទួលបានសំណុំរឿងក្នុងការសម្រេចសេចក្ដីច្រើនជាងមជ្ឈត្តការរបស់ប្រទេសកម្ពុជា។ ដោយសារតែសមត្ថភាពប្រព័ន្ធមជ្ឈត្តការរបស់ប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីនៅមានកម្រិតកង្វះធនធានរួមផ្សំទាំងកង្វះខាតនៃសកម្មភាពអប់រំ និងផ្សព្វផ្សាយទាក់ទងនឹងវិស័យមជ្ឈត្តការផងទើបប្រទេសកំពុង

---

[136] *Food Ingredients LCC v. Pacific Inter-Link Sdn Bhd* (High Court of Malaysia, 2012), 8 MLJ 585។

[137] *Food Ingredients LCC v. Pacific Inter-Link Sdn Bhd* (High Court of Malaysia, 2012), 8 MLJ 585។

[138] Rajoo, Sundra, Choong Yeow Choy. "The Arbitration Regime in Malaysia: A De Jure Model Law Jurisdiction?", *The UNCITRAL Model Law and Asian Arbitration Laws* (Cambridge University Press 2018) ទំព័រទី១៧៥។

[139] ផ្នែកទី៣៩(១)(ក)(ii) នៃច្បាប់ស្ដីពីមជ្ឈត្តការរបស់ម៉ាឡេស៊ី, ៣០ ធ្នូ ២០០៥។

អភិវឌ្ឍន៍ នៅមានបញ្ហាប្រឈមទាក់ទងនឹងបញ្ហាសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការមកដល់ពេលបច្ចុប្បន្ននៅឡើយ៕

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាទូទៅ មជ្ឈត្តកាសម្រាប់ដោះស្រាយជម្លោះតាមយន្តការក្រៅប្រព័ន្ធតុលាការនីមួយៗគឺមានការបង្កើតឡើងក្នុងទម្រង់ស្រដៀងគ្នាទោះបីជាប្រព័ន្ធច្បាប់របស់ខ្លួនដូចគ្នាឬខុសគ្នាក៏ដោយ។ ចំពោះប្រទេសកម្ពុជាបានបង្កើតមជ្ឈត្តការពាណិជ្ជកម្មឡើងនៅឆ្នាំ២០០៦ ក្នុងបំណងសម្រួលដល់ការដោះស្រាយជាបញ្ហាតាមរយៈការផ្សះផ្សារនូវវិវាទពាណិជ្ជកម្ម ដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមការស្ម័គ្រចិត្តរបស់ភាគីនៃវិវាទ ដើម្បីការពារសិទ្ធិរួមទាំងផលប្រយោជន៍របស់ភាគីវិវាទនិងដើម្បីចូលរួមលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិកម្ពុជាមួយផ្នែកផងដែរ។ ចំណែកឯប្រទេសម៉ាឡេស៊ីវិញ គឺបានកែប្រែច្បាប់និងប្រព័ន្ធមជ្ឈត្តការរបស់ខ្លួនមួយចំនួននៅឆ្នាំ២០១៨ ដើម្បីសម្របទៅតាមបរិបទមជ្ឈត្តការទំនើបនាពេលបច្ចុប្បន្នរួមផ្សំនឹងទាំងការផ្តល់ជូននូវភាពងាយស្រួលក្នុងការដោះស្រាយវិវាទនៅតាមប្រព័ន្ធមជ្ឈត្តការរបស់ខ្លួន។

ទន្ទឹមនឹងការបង្កើតប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្មស្របតាមលិខិតបទដ្ឋានគតិយុត្តិដែលច្បាប់តម្រូវ គួបផ្សំនឹងការបង្កើតភ្ជាប់ជាមួយរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងប្រព័ន្ធមជ្ឈត្តការស្របតាមស្តង់ដា និងតម្រូវការរបស់មជ្ឈត្តការអន្តរជាតិដែលទទួលស្គាល់អំពីការអនុវត្តជាសកលក៏ដោយ មជ្ឈត្តការនៅតែមានបញ្ហាគតិយុត្តមួយចំនួនកើតមានឡើងជារឿយៗ ដូចជាករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ហេតុដូច្នេះហើយទើបដំណើរការប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម នៅមានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនជាពិសេសគឺទាក់ទងនឹងលក្ខខណ្ឌសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយសារតែវាពិតជាមានសារៈសំខាន់និងមានឥទ្ធិពលលើសុពលភាពនិងការដែលអាចអនុវត្តបាន។ ពីព្រោះការរាល់ការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការផ្នែកពាណិជ្ជកម្មដោយការមិនបានគិតគូរដល់លក្ខខណ្ឌទម្រង់ លក្ខខណ្ឌសារជាតុ និងលក្ខខណ្ឌគ្រឹះផ្សេងៗទៀតនឹងជះឥទ្ធិពលមិនល្អ រួមទាំងអាចបង្កឲ្យមានផលវិបាកច្រើនចំពោះគូភាគីក្នុងដំណើរការដោះស្រាយវិវាទរបស់ខ្លួន។

ដោយផ្អែកលើ បញ្ហាសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលច្រើនកើតមានជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី ការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាពតាមរយៈការចែករំលែកនូវចំណេះដឹងពីអ្នកជំនាញនិងមានបទពិសោធន៍ក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្ម ឬការបង្កើតជាវគ្គបណ្តុះបណ្តាលដល់មជ្ឈត្តករ មេធាវី ពាណិជ្ជករនានាពិតជាចាំបាច់ដើម្បីឲ្យអ្នកអនុវត្តនិងភាគីពាក់ព័ន្ធបានយល់ដឹងបន្ថែម ដើម្បីចូលរួមកាត់បន្ថយនូវការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដែលអសុពលភាព។ ម៉្យាងវិញទៀត ការកាត់បន្ថយអសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនឹងផ្តល់ប្រយោជន៍ទាំងការចំណេញថវិកានិងពេលវេលារបស់គូភាគី ក៏ដូចជាចូលរួមពង្រឹងគុណភាពប្រព័ន្ធមជ្ឈត្តការនៅប្រទេសកំពុងអភិវឌ្ឍន៍ឲ្យកាន់តែប្រសើរឡើងប្រកបដោយភាពជោគជ័យដូចគ្នាទៅនឹងមជ្ឈត្តការពាណិជ្ជកម្មនៅប្រទេស

អភិវឌ្ឍ។ ជាចុងក្រោយ អ្នកវិនិយោគទាក់ទងនឹងវិស័យពាណិជ្ជកម្មទាំងក្នុងប្រទេសនិងក្រៅប្រទេសនឹងធ្វើការវិនិយោគកាន់តែច្រើនរួមទាំងពង្រីកទីផ្សាររបស់ពួកគេ នៅក្នុងប្រទេសណាដែលមានច្បាប់និងបទប្បញ្ញត្តិទាក់ទង នឹងវិស័យពាណិជ្ជកម្មដើម្បីការពារផលប្រយោជន៍ពាណិជ្ជកម្ម និងមានការផ្តល់នូវការដោះស្រាយវិវាទតាម ប្រព័ន្ធមជ្ឈត្តការផ្នែកពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាពនិងរហ័ស ដោយសារតែពួកគេជឿជាក់ថាប្រទេសទាំងអស់នោះផ្តល់នូវស្ថានភាពអំណោយផលដល់ការធ្វើពាណិជ្ជកម្មប្រកបដោយសុវត្ថិភាព។ យោងលើហេតុផលទាំងនេះ ទើបប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគួរតែកែប្រែនូវចំណុចខ្វះខាតនិងពង្រឹងសមត្ថភាពនៃប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្មរបស់ខ្លួនបន្ថែម ពីព្រោះវាក៏ជាកត្តាចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិយ៉ាងសកម្មដូចគ្នា។

# អនុសាសន៍

# អនុសាសន៍

ជាអនុសាសន៍ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងទាក់ទងនឹងសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសក្នុងករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីគឺភាគីត្រូវបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម ស្របតាមធាតុផ្សំនៃច្បាប់ដែលគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មទាំងលក្ខខណ្ឌទម្រង់ លក្ខខណ្ឌសារធាតុនិងលក្ខខណ្ឌគ្រឹះដោយភ្ជាប់ទីកន្លែងនៃការដោះស្រាយវិវាទពាណិជ្ជកម្ម(អាសនៈនៃមជ្ឈត្តការ)។ ជាដំបូងកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មត្រូវតែចែងឲ្យច្បាស់ថាវិវាទពាណិជ្ជកម្មទាំងឡាយដែលភាគីបានព្រមព្រៀងគ្នានៅពេលឬបានកើតឡើង គឺត្រូវតែដោះស្រាយដោយប្រព័ន្ធមជ្ឈត្តការពាណិជ្ជកម្ម។ លើសពីនេះទៅទៀត ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគួរតែក៏តែប្រយ័ត្ននិងជៀសវាងទាក់ទិននឹងការព្រមព្រៀងណា ដែលមានការប៉ះពាល់ដល់ច្បាប់ឬវិធានមជ្ឈត្តការណាដែលភាគីត្រូវគោរពតាមឬអាចអនុវត្តបាន។ ចំណុចដែលសំខាន់ជាងនេះទៅទៀត គឺទាក់ទងនឹងដំណាក់កាលនៃការទទួលស្គាល់ និងប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសគឺភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគួរតែជៀសវាងនូវការព្រមពៀងណា ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេសពាក់ព័ន្ធដូចជាៈប្រទេសដែលជាទីតាំងមជ្ឈត្តការឬអាសនៈនៃមជ្ឈត្តការ ក៏ដូចជាប្រទេសដែលត្រូវប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសជាដើម។ ពីព្រោះនៅពេលដែលកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មអសុពលភាពដោយសារតែមានចែងនូវចំណុចណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេសពាក់ព័ន្ធទោះបីជាមានការសម្រេចសេចក្តីពីមជ្ឈត្តករក៏ដោយ ទីបំផុតតុលាការនៃប្រទេសពាក់ព័ន្ធដែលភាគីត្រូវធ្វើការស្នើសុំទទួលស្គាល់និងប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករនឹងធ្វើការបដិសេធជាក់ជាមិនបាន។

ជាអវសានកថានៃសារណា នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាចំណុចដែលនាងខ្ញុំបានលើកឡើងជាដំណោះស្រាយទាក់ទងនឹងបញ្ហាប្រឈមនៃសុពលភាពកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម នៅប្រទេសកំពុងអភិវឌ្ឍន៍ក្នុងករណីប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ី គឺអាចចូលរួមជួយកាត់បន្ថយបញ្ហានេះទាំងក្នុងអំឡុងពេលបច្ចុប្បន្ននិងពេលអនាគតថែមទៀត។ នាងខ្ញុំក៏សំណូមពរឲ្យភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្ម និងបុគ្គលដែលពាក់ព័ន្ធទាំងអស់ គួរតែព្យាយាមជៀសវាងនូវចំណុចដែលនាងខ្ញុំបានរៀបរាប់ឡើងដោយភ្ជាប់នឹងហេតុផលរួមទាំងផលវិបាកដែលអាចនឹងជួបប្រទះផងដែរ ពីព្រោះការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មដោយមិនមានអសុពលភាព គឺផ្តល់និងការពារប្រយោជន៍ជាច្រើនទៅដល់ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តការពាណិជ្ជកម្មគ្រប់រូបដោយសារតែវាចំណេញពេលវេលានិងថវិការបស់ពួកគាត់។ ជាងនេះទៅទៀត ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការពាណិជ្ជកម្មក៏សមស្របនឹងយុត្តិសាស្ត្ររបស់ប្រទេសនីមួយៗ ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ នៅពេលដែលមានការធ្វើសកម្មភាពពាណិជ្ជកម្មកាន់ច្រើនពីសំណាក់ពាណិជ្ជករទាំង

ក្នុង និងក្រៅប្រទេស ដោយសារតែពួកគាត់មានជំនឿទុកចិត្តចំពោះច្បាប់និងប្រព័ន្ធនៃការដោះស្រាយវិវាទពាណិជ្ជកម្មដែល ឯករាជ្យមិនមានភាពលម្អៀងប្រកបដោយប្រសិទ្ធភាព និងមានភាពឆាប់រហ័សខុសពីតុលាការជាតិ។

# ឯកសារយោង

# ឯកសារយោង

- **ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ**

## ច្បាប់ និងបទប្បញ្ញត្តិអន្តរជាតិ

១. គម្រូច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ( UNCITRAL Model Law on International Commercial Arbitration), ១៩៨៥(វិសោធនកម្ម២០១៦ )។

២. គោលការណ៍UNIDROITនៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ( UNIDROIT Principles of International Commercial Contracts), ២០១៦។

៣. អនុសញ្ញាស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ឬអនុសញ្ញាទីក្រុងញូវយ៉ក(Convention on the Recognition and Enforcement of Foreign Arbitral Awards or New York Convention), ១៩៥៨។

៤. អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាសម្រាប់ការលក់ទំនិញអន្តរជាតិ( United Nations Convention on Contracts for the International Sale of Goods), ១៩៨០។

៥. Guide on the Convention on the Recognition and Enforcement of Foreign Arbitral Awards, ២០១៦។

៦. UNCITRAL Digest of Case Law on the Model Law on International Commercial Arbitration, ២០១២។

៧. UNCITRAL Digest of Case Law on the United Nations Convention on the International Sale of Goods, ២០១២។

## ច្បាប់ និងបទប្បញ្ញត្តិជាតិ

១. ក្រមរដ្ឋប្បវេណីកម្ពុជា( Civil Code of Cambodia), នស/ រកម/ ១២០៧/ ០៣០, ០៥ តុលា ២០០៧។

២. ច្បាប់កិច្ចសន្យាម៉ាឡេស៊ី(Malaysia Contracts Act), ១៩៥០។

៣. ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា(Commercial Arbitration Law of Cambodia), នស/ រកម/ ០៥០៦/ ០១០, ០៥ ឧសភា ២០០៦។

៤. ច្បាប់ស្តីពីមជ្ឈត្តការម៉ាឡេស៊ី(Malaysia Arbitration Act), ៣០ ធ្នូ ២០០៥។

៥. ច្បាប់ស្តីពីនីតិភាព(Age of Majority Act), ២២ មេសា ១៩៧១។

៦. ច្បាប់ស្តីពីការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស, នស/ រកម/ ០៧០១/ ១០, ២៣ កក្កដា ២០០១។

៧. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ១២៤ អនក្រ.បក, ១២ សីហា ២០០៩។

៨. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម(Arbitration Rules of the National Commercial Arbitration Centre of Cambodia), ១១ កក្កដា ២០១៤។

៩. វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ី(Arbitration Rules of Asian International Arbitration Centre), ៩ មីនា ២០១៨។

- **សេចក្តីសម្រេច**

១. Food Ingredients LCC v. Pacific Inter-Link Sdn Bhd, ឆ្នាំ2012, តុលាការជាន់ខ្ពស់នៃប្រទេស ម៉ាឡេស៊ី, លេខសំណុំរឿង: 8 MLJ 585 ។

- **សៀវភៅ**

១. Berg, Albert Jan van den. ១៩៨១. *Th New York Arbitration Convention of 1958,* Kluwer Law International។

២. Born, Gary B. ២០១៤. *International Commercial Arbitration*. London: Kluwer Law International។

៣. Fouchard, Philippe, Gailard Emmanuel, Goldman Berthold. ១៩៩៩. *International Commercial Arbitration*. London: Kluwer Law International។

៤. Mistelis Loukas A. ២០១៤. *CISG and Arbitrtion*. Cambridge University Press។

៥. Moses, Margaret L. ២០០៨. *Th Principles and Practice of International Commercial Arbitration*. Cambridge University Press ។

៦. Redfern Alan, Hunter Martin, Blackaby Niegel, Partasides Constantine. ២០១៥. *Redfern and Hunter on International Arbitration.* Oxford University Press។

- **ឯកសារផ្សេងៗ**


**អត្ថបទព្រឹត្តិបត្រ**

១. Conventus Law. ២០១៨. "Legal News & Analysis- Asia Pacific – Malaysia- Dispute Resolution", *KLRCA Officially Renamed the Asian International Arbitration Centre*។

២. Raghavan, Vikram. ២០១៨. "Heightened Judicial Review of Arbitral Awards: Perspectives from the UNCITRAL Model Law and the English Arbitration Act of 1996 on some US Developments", *Journal of International Arbitration*. Kluwer Law International។

៣. Rajoo, Sundra, Choong Yeow Choy. ២០១៨. "The Arbitration Regime in Malaysia: A De Jure Model Law Jurisdiction?", *Th UNCITRAL Model Law and Asian Arbitration Laws*. Cambridge University Press។

៤. Sanchez, Wilder Alejandro &Scripcari Lucia. ២០១៩. "The New Arbitration Centers…", *Battle of the Seats: Developing Nations and International Arbitration Centers.* Geopolitical Monitor ។

- **គេហទំព័រផ្លូវការ**

១. Asian International Arbitration Centre: https://www.aiac.world/About-AIAC-

